# *ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៨*

## ជនសង្ស័យជនជាតិចិនចំនួន២នាក់ កំពុងដើរផ្សព្វផ្សាយចែកខិតប័ណ្ណមានរូបអាសអាភាពបង្កប់ន័យបម្រើសេវាផ្លូវភេទ ត្រូវនគរបាលចាប់ខ្លួន

http://cambodiapolice.com/policekh/ 4:45 pm 6 កញ្ញា 2018 81

**ព្រះសីហនុ៖** លោកឧត្តមសេនីយ៍ទោជួន ណារិន្ទ ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុឱ្យដឹងថា កាលពីម៉ោងជិត០១យប់រំលងអាធ្រាត្រឆ្លងចូលថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន សហការជាមួយកម្លាំងអធិការដ្ឋាននគរបាលក្រុងព្រះសីហនុ បានឃាត់ខ្លួនជនសង្ស័យជនជាតិចិនចំនួន២នាក់ កំពុងដើរផ្សព្វផ្សាយចែកខិតប័ណ្ណមានរូបអាសអាភាពបង្កប់ន័យបម្រើសេវាផ្លូវភេទ នៅចំណុចផ្ទេរអូរឈើទាល ក្នុងសង្កាត់៤ ក្រុងព្រះសីហនុ ។

ជនសង្ស័យទី១-ឈ្មោះ HUANG JI ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិចិន (គ្មានលិខិតឆ្លងដែនជាប់ខ្លួន) ទី២-ឈ្មោះ XIA LU ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិចិន (គ្មានលិខិតឆ្លងដែនជាប់ខ្លួន) ។ ក្រោយពីបានឃាត់ខ្លួនកម្លាំងជំនាញបានឈានទៅធ្វើការឆែកឆេរកន្លែងស្នាក់នៅរបស់ជនសង្ស័យ នៅហាងម៉ាស្សា យីហោ SPA ស្ថិតក្នុងក្រុមទី២ ភូមិ៤ សង្កាត់៤ ក្រុងព្រះសីហនុ ដោយបាននាំខ្លួនស្ត្រីជនជាតិចិនចំនួន១០នាក់ នៅក្នុងហាងម៉ាស្សា មកធ្វើការសាកសួរ។ ដកហូតបានវត្ថុតាង៖-ខិតប័ណ្ណមានរូបអាសអាភាស៧២ប្រអប់ (១ប្រអប់ស្មើនឹង៥០០សន្លឹក),-សៀវភៅកត់ត្រា ៣ក្បាល,-ស្រោមអនាម័យមិនទាន់ប្រើចំនួន ៨០ស្រោម,-ស្រោមអនាម័យប្រើរួចចំនួន ០៥ស្រោម,-អាយផេត ម៉ាក Dinabook ១គ្រឿង,-កាបូបដាក់ស្រោមអនាម័យចំនួន៣,-វិទ្យុទាក់ទងម៉ាក Magaband ចំនួន៣គ្រឿង។

បច្ចុប្បន្នជនសង្ស័យទាំង២នាក់ និងស្ត្រីចំនួន ១០នាក់ត្រូវបានកម្លាំងជំនាញកំពុងធ្វើការសាកសួរតាមនីតិវិធី នៅការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្ត៕

## ណែនាំដល់ម្ចាស់អាជីវកម្ម ក្លឹបឱស្ថ ខារ៉ាអូខេ មិនត្រូវចែកចាយ ប័ណ្ណរូបភាពអាសអាភាស និងអនុវត្តន៍ច្បាប់ប្រទេសកម្ពុជា

http://www.cen.com.kh/archives/ September 12, 2018

ព្រះសីហនុ ៖ ស្នងការនគរបាលខេត្តព្រះសីហនុ បានណែនាំដល់ម្ចាស់អាជីវកម្ម ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ឲ្យម្ចាស់អាជីវកម្មទាំងអស់ ត្រូវគោរពតាមលក្ខខណ្ឌច្បាប់ នៃប្រទេសកម្ពុជា ជាពិសេសម្ចាស់ក្លឹបឱស្ថ ខារ៉ាអូខេ ត្រូវគោរពច្បាប់ទីតាំងត្រូវមានប្រព័ន្ធគ្រប់គ្រងសន្តិសុខ សុវត្ថិភាព កម្លាំងសន្តិសុខឯកជន ត្រូវមានឯកសារអត្តសញ្ញាណប័ណ្ណត្រឹមត្រូវ។ ម្ចាស់អាជីវកម្ម មិនត្រូវចែកចាយ ប័ណ្ណរូបភាពអាសអាភាស មិនត្រូវឆ្លៀតឱកាសយកទីតាំងទៅ រកស៊ីប្រព្រឹត្តបទល្មើសខុសច្បាប់ ជួញដូរមនុស្ស ជួញដូរប្រើប្រាស់គ្រឿងញៀន និងបនពេស្យាចារដាច់ខាត។

លោកឧត្តមសេនីយ៍ទោ ជួន ណារិន្ទ ស្នងការនគរបាលខេត្ត បានជួបសំណេះសំណាល ពិភាក្សាការងារជាមួយម្ចាស់អាជីវកម្មនៅក្នុងក្រុងព្រះសីហនុ នៅរសៀលថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨ នៅស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ដោយមានមានការចូលរួមពីមន្ត្រីនគរបាលផែនជំនាញ ម្ចាស់អាជីវកម្ម ដូចជា សណ្ឋាគារ-កាស៊ីណូក្លឹបកម្សាន្ត ខារ៉ាអូខេ និងម៉ាស្សា ចូលរួមសរុប ៨៤នាក់ (ជនជាតិខ្មែរ ៦៣នាក់ ចិន២០នាក់ និងកូរ៉េ១នាក់)។ លោកឧត្តមសេនីយ៍ទោ ជួន ណារិន្ទ ស្នងការនគរបាលខេត្ត បានឱ្យដឹងថាគោល បំណងសំខាន់នៅក្នុងជំនួប

ពិភាក្សាការងារជាមួយម្ចាស់អាជីវកម្ម ដើម្បីពង្រឹងប្រសិទ្ធភាព នៃការអនុវត្តច្បាប់ ឲ្យម្ចាស់អាជីវកម្មទាំងអស់ ត្រូវគោរពតាមលក្ខខណ្ឌច្បាប់ នៃប្រទេសកម្ពុជា មិនត្រូវយកទីតាំងរបស់ខ្លួន ប្រព្រឹត្តបទល្មើសជាដាច់ខាត។

លោកស្នងការ បានសំណូមពរ ឲ្យអាជីវករទាំងអស់ ទាំងខ្មែរ និងបរទេស ត្រូវគោរពច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ចំពោះអ្នកប្រើប្រាស់យានយន្ត ត្រូវគោរពស្លាកសញ្ញា ច្បាប់ចរាចរណ៍ផ្លូវគោក។ ជនបរទេសដែលប្រើប្រាស់ប័ណ្ណបើកបរក្លែងក្លាយនិងជន ខិលខូច ផ្តល់ឯកសារក្លែងក្លាយឲ្យ អ្នកទាំងនោះ ត្រូវមានទោស ពីបទក្លែងឯកសារសាធារណៈនិងប្រើប្រាស់ឯកសារខុសច្បាប់ ត្រូវមានទោស មិនអាចលើកលែងបានឡើយ ។ ក្លឹបឌីស្កូ ខារ៉ាអូខេ ត្រូវគោរពច្បាប់ទីតាំងត្រូវមានប្រព័ន្ធគ្រប់គ្រងសន្តិសុខ សុវត្ថិភាព កម្លាំងសន្តិសុខឯកជនត្រូវមានឯកសារអត្តសញ្ញាណប័ណ្ណ ត្រឹមត្រូវ។ ម្ចាស់អាជីវកម្ម មិនត្រូវចែកចាយ ប័ណ្ណរូបភាពអាសអាភាស មិនត្រូវឆ្លៀតឱកាស យកទីតាំងទៅ រកស៊ីប្រព្រឹត្តបទល្មើសខុសច្បាប់ ជួញដូរមនុស្ស និងជួញដូរប្រើប្រាស់ គ្រឿងញៀន បើកបន ពេស្យាចារដាច់ខាត។ ត្រូវមានការយោគយល់ គោរពច្បាប់ទាំងអស់គ្នា រួមគ្នា ការពារសុវត្ថិភាព សន្តិសុខ ដើម្បីការពារអភិវឌ្ឍន៍ខេត្តព្រះសីហនុ របស់យើង ឲ្យមានការរីកចម្រើន មានសន្តិសុខសណ្តាប់ សុវត្ថិភាពល្អ ៕ ដោយ ៖ បញ្ញាស័ក្តិ

## តុលាការកំពូល ជម្រះក្តីឡើងវិញលើរឿងបុរសអង់គ្លេស រំលោភក្មេងស្រី

https://www.postkhmer.com/ គឹម សារុំ | Publication date 11 September 2018 | 09:33 ICT

**ភ្នំពេញៈ** តុលាការកំពូលកាលពីម្សិលមិញបានបើកសវនាការលើបណ្តឹងសើរើជនបរទេសម្នាក់ដោយកំបាំងមុខមកជំនុំជម្រះដោយមិនមានវត្តមានទណ្ឌិតរូបនេះដែលតុលាការកំពូលប្រកាសតម្កល់សាលដីកាឲ្យជាប់គុក ១០ ឆ្នាំម្តងមកហើយរឿងរំលោភកុមារីកម្ពុជា ដែលប្រព្រឹត្តកាលពីឆ្នាំ ២០០៩ នៅរាជធានីភ្នំពេញ។ លោកព្រះរាជអាជ្ញាឧប គឹមសន ជាតំណាងមហាអយ្យការបានសន្និដ្ឋានថា ទណ្ឌិតឈ្មោះ David Jonh Flecher ត្រូវបានសាលាដំបូងរាជធានីភ្នំពេញកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេល ១០ ឆ្នាំ។ ប៉ុន្តែទណ្ឌិតរូបនេះមិនសុខចិត្តក៏ប្តឹងបន្តទៅសាលាឧទ្ធរណ៍ទៀតតែត្រូវសាលាឧទ្ធរណ៍សម្រេចតម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញឲ្យទណ្ឌិតរូបនេះជាប់ទោស ១០ ឆ្នាំដដែល។ ទណ្ឌិតនេះនៅតែមិនសុខចិត្តក៏ប្តឹងសារទុក្ខមកតុលាការកំពូលហើយត្រូវតុលាការកំពូលសម្រេចតម្កល់ទោស ១០ ឆ្នាំដដែល។

លោក គឹមសន ថ្លែងថា៖ «ប៉ុន្តែបើផ្អែកលើអង្គហេតុបង្ហាញថា ទណ្ឌិតរូបនេះមិនបានប្រព្រឹត្តទេ។ សូមក្រុមប្រឹក្សាជំនុំជម្រះពិចារណាតាមច្បាប់»។

លោក ស្រី ម៉ុន វិមានចំប៉ា ជាមេធាវីការពារសិទ្ធិឲ្យលោក David បានឯកភាពតាមលោកតំណាងមហាអយ្យការ។ លោកស្រីថា៖ «ព្រោះបើតាមលិខិតពីគ្រូពេទ្យបញ្ជាក់ថាសន្ទះព្រហ្មចារីរបស់ក្មេងស្រីនោះនៅល្អ គ្មានដាច់រហែកទេ ខ្ញុំសូមតុលាការដោះលែងគាត់ដើម្បីឲ្យគាត់បានទៅស្រុកព្យាបាលជំងឺរបស់គាត់»។

ទណ្ឌិតឈ្មោះ David អាយុ ៧៧ ឆ្នាំជាជនជាតិអង់គ្លេសបានរំលោភកុមារីកម្ពុជាម្នាក់អាយុ ១៦ ឆ្នាំក្រោយប្រព្រឹត្តរួចជនជាប់ចោទបានរត់គេចខ្លួនទៅប្រទេសថៃ ហើយក៏ចាប់ខ្លួនបានវិញកាលពីអំឡុងឆ្នាំ ២០១០។ សាលដីកានេះនឹងប្រកាសនៅថ្ងៃទី ១៧ កញ្ញា ខាងមុខ៕

## ការសែតវៀតណាម៖ ថៃនឹងអនុញ្ញាតឲ្យពលករ ខុសច្បាប់វៀតណាម ធ្វើការក្នុងប្រទេស ខ្លួនបាន

https://www.dap-news.com/ ByID:115 Posted on September Thu, 2018 13:02

បរទេស៖ យោងតាមកាសែតថៃ បានឱ្យដឹងថា ដើម្បីទាក់ទាញពលករ ចំណាកស្រុក មកពីប្រទេសវៀតណាម គឺរដ្ឋាភិបាលថៃ បានអនុម័តលើ សំណើសុំអាជ្ញាប័ណ្ណ ឱ្យពលករវៀតណាម ខុសច្បាប់អាចធ្វើការនៅក្នុងប្រទេសថៃបាន។ យោងតាមសារព័ត៌មាន BBC ចេញផ្សាយកាលពីថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៨ បានឲ្យដឹងថា កាសែតបាងកកប៉ុស្ដិ៍ បានដកស្រង់សម្ដីរដ្ឋមន្ត្រីក្រសួង ការងារថៃ គឺលោក Adul Sangsingkeo ថា «សំណើនេះ

តម្រូវឱ្យកម្មករខុសច្បាប់ ជាលើកដំបូង ត្រូវត្រឡប់ទៅប្រទេសវៀតណាមវិញ ហើយទើប ត្រឡប់មកប្រទេសថៃ ជាមួយនឹងប័ណ្ណការងារ»។ សំណើនេះផ្តល់អត្ថប្រយោជន៍ដល់ ប្រជាពលរដ្ឋវៀតណាមចំនួន ៥០.០០០នាក់ ដែលនឹងអនុញ្ញាតនៅក្នុងប្រទេសថៃក្នុងរយៈពេល ៣០ថ្ងៃ ជាទិដ្ឋាការទេសចរណ៍ ហើយនៅតែបន្តធ្វើការខុសច្បាប់។ បញ្ជីការងារសម្រាប់ពលរដ្ឋវៀតណាម ដែលត្រូវបាន គេផ្តល់ការងារធ្វើឱ្យប្រទេសថៃបន្ថែមនោះ គឺមានការងារផ្ទះ និងពលករផ្សេងៗ ចំណែក ឧស្សាហកម្ម នៅប្រទេសថៃ គឺបើកទូលាយសម្រាប់ ពលករវៀតណាម នោះគឺផ្នែកសណ្ឋាគារ និងទេសចរណ៍។

សូមជម្រាបថា គោលនយោបាយដូចគ្នានេះ ក៏ត្រូវបានអនុវត្តចំពោះ ពលករចំណាកស្រុកមកពីឡាវ មីយ៉ាន់ម៉ា និងកម្ពុជា។ ប៉ុន្តែអាចធ្វើទៅបាន គឺក្រោយពេលដែលថៃ បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ (MOU) ជាមួយប្រទេសទាំងបួន ទៅលើកិច្ចសហប្រតិបត្តិការ ផ្តល់ការងារ បន្ថែមមកប្រទេសថៃ៕ ប្រែសម្រួលៈ ណៃ តុលា

## ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨

### ពលករខ្មែរម្នាក់ ជួបគ្រោះថ្នាក់ចរាចរណ៍នៅថៃបណ្តាលឲ្យស្លាប់នៅនឹងកន្លែង

https://chsknews.com/ By មាណព បុល - September 13, 2018

ថៃ៖ កាលពីវេលាម៉ោង៧និង៣០នាទី យប់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨ លើកំណាត់ផ្លូវលេខ៣០១៧ ក្បែរវត្តខ្លងហ្វក្រុត ស្ថិតក្នុងភូមិ៥ ឃុំបាងតេជៈ ស្រុកមឿង ខេត្តប្រាជីនបុរី ប្រទេសថៃ រវាងម៉ូតូហុងដាវេវ ធុនសេ ១០០ ពាក់ស្លាកលេខ ប្រាជីនបុរី ៥៧៥៣ ដែលបើកបរដោយពលករខ្មែរ រស់នៅប្រទេសថៃ ជាមួយនឹងម៉ូតូម៉ាក យ៉ាម៉ាហា ពាក់ស្លាកលេខ ប្រាជីនបុរី ៦៦៧ បើកបរដោយជនជាតិថៃ។

បុរសពលករខ្មែរម្នាក់ បានស្លាប់ភ្លាមៗនៅនឹងកន្លែងកើតហេតុ ក្នុងចំណោមមនុស្សស្លាប់ចំនួន២នាក់ ខណៈពួកគេបានបើកបរម៉ូតូទាំងផ្លូវថ្នល់ទើបនឹងភ្លៀងរួចថ្មីៗ ហើយសង្ស័យពួកគេអាចប្រើប្រាស់ល្បឿនលឿន និងគួបផ្សំទៅលើផ្លូវ ដែលមានសភាពរអិលផង។ នៅមុនពេលកើតហេតុ គឺមេឃបានធ្លាក់ភ្លៀងមួយមេយ៉ាងខ្លាំង ក៏ស្រាប់តែឮសំឡេងប៉ះទង្គិចគ្នាប្រាវតែម្តង នៅពេលដែលអ្នកភូមិចេញមកមើល គឺឃើញមានមនុស្សដេកស្លាប់រៀងៗខ្លួនទៅហើយ ដែលម្នាក់ៗមានឈាមពេញខ្លួនប្រាណ ទើបពួកគេបានប្តឹងទៅសមត្ថកិច្ចចរាចរណ៍តែម្តង។ ស្ត្រីម្នាក់ដែលជាភរិយារបស់សពពលករខ្មែរ បាននិយាយថា ប្តីរបស់ខ្លួនឈ្មោះ សូ សៅម៉ក់ អាយុ៣០ឆ្នាំ ជាកម្មករក្នុងកសិដ្ឋានចិញ្ចឹមត្រី ហើយគាត់បានចេញម៉ូតូទៅទិញទឹកកក។ លុះត្រឡប់មកវិញ ក៏ជួបនឹងគ្រោះថ្នាក់តែម្តង។ ដោយឡែក ភាគីម្ខាងទៀត គឺលោក ដាំរ៉ុង ផៃចន្ទ្រ ជាឪពុកសព បាននិយាយថា កូនប្រុសរបស់លោកឈ្មោះ ណុបយុន ផៃចន្ទ្រ អាយុ១៥ឆ្នាំ គឺគេបានចេញម៉ូតូទៅទិញកាតទូរស័ព្ទ ក៏ជួបនឹងគ្រោះថ្នាក់ដូចគ្នា។

ក្រុមតម្រួតចរាចរណ៍ បាន និងកំពុងពិនិត្យ ដើម្បីចង់ដឹងថា តើមូលហេតុអ្វីបានជាធ្វើឲ្យពួកគេទាំង២នាក់ បើកបរប៉ះទង្គិចគ្នាខ្លាំងបែបនេះ ព្រោះភាគីខ្មែរ ប៉ះទង្គិចរហូតផុងលលាដ៏ក្បាល ខណៈភាគីថៃ បែកក្បាល និងបាក់ជើងឆ្វេងម្ខាង ចេញឆ្អឹងមកខាងក្រៅ។

## ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៨

## ជួយស៊ែរឲ្យសាច់ញាតិគាត់ដឹងផង អាណិតណាស់ជីវិតពលករខ្មែររស់នៅស្រុកគេ ទៅជាអកុសលយ៉ាងខ្លោចផ្សាឲ្យគ្រួសារបែរជាស្លាប់ទៅវិញ

http://isharetoday.com/archives/ POSTED BYRO GERSEPTEMBER 13, 2018

តាមរយៈគណនីហ្វេសប៊ុកមួយបានបង្ហោះរូបបុរសម្នាក់ដែលជាពលករខ្មែរធ្វើការនៅប្រទេសកូរ៉េបានស្លាប់យ៉ាងអណោចអាធម៌ដោយសារឡានកាយដីកិន ។ ខាងក្រោមជាសារដែលគាត់បានបង្ហោះ« គាត់បានស្លាប់ហើយបើបងប្អូនណាស្គាល់ក្រុមគ្រួសាររបស់គាត់ជួយប្រាប់ផង(គាត់ឈ្មោះវឌ្ឍនៈ)គ្រោះថ្នាក់ការងារនៅម៉ុំ부산 ជួយគ្នាយកតែបុណ្យទៅ 13/09/2018 បញ្ជាក់ឡានកាយដីកិនអាណិតគាត់ណាស់ខ្ញុំអួលដើមកលឺដំណឹងនេះ» ។ ម្ចាស់ហ្វេសប៊ុកបានសរសេរបន្តថា « RIP ពលករឈ្មោះឈឿម សេរីវឌ្ឍនះ អាយុ៣៣ឆ្នាំ ផ្នែកសំណង់ គ្រោះថ្នាក់ការងារត្រូវអាអុិចកិន បានស្លាប់បាត់បង់ជិវិតហើយ តាមការបង្ហោះរបស់មិត្តរួមការងារនៅការដ្ឋានធ្វើការជាមួយគ្នានៅតំបន់ ប៊ូសាន ។ គាត់មានស្រុកកំណើត ភូមិទួលតាឯក ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង សូមចូលរួមរំលែកទុក្ខ នឹងសោកស្តាយ » ៕

## យល់ដឹងផ្នែកច្បាប់៖ ការសុំកូន

http://www.freshnewsasia.com/index. 2018-09-16

**(ភ្នំពេញ)៖** បុរស-នារីដែលមានគោលបំណងរៀបអាពាហ៍ពិពាហ៍បង្កើតជាគ្រួសារមួយ គឺផ្តើមចេញសេចក្តីស្រលាញ់របស់អ្នកទាំងពីរ បន្ថែមពីនេះគោលបំណងចំបងមួយទៀត នៃអាពាហ៍ពិពាហ៍ គឺការបង្កើតកូនសម្រាប់បន្តវង្សត្រកូល។ ប៉ុន្តែគ្រប់គ្រួសារទាំងអស់មិនប្រាកដថា នឹងអាចសម្រេចបាននូវគោលបំណងក្នុងការបង្កើតកូនបន្តពូជពង្សបាននោះទេ ដែលបញ្ហានេះភាគច្រើនកើតចេញពីកត្តាវេជ្ជសាស្ត្រ។ ក្នុងករណីដែលប្តីប្រពន្ធនៃគ្រួសារមួយមិនអាចបង្កើតកូនដោយខ្លួនឯងបាន ពួកគេអាចស្វែងរកសុំកូនរបស់អ្នកដទៃ ឬ កូនរបស់សាច់ញាតិខ្លួនឯងមកចិញ្ចឹមបាន ដែលសកម្មភាពនៃការសុំកូននេះ ក្នុងច្បាប់ត្រូវបានហៅថា **«ការសុំកូន»**។

**ដើម្បីឲ្យយល់កាន់តែច្បាស់អំពី «ការសុំកូន» ថាតើការសុំកូនអាចធ្វើឡើងតាមវិធីណាខ្លះ និងត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ? កម្មវិធីយល់ដឹងផ្នែកច្បាប់របស់អង្គភាពព័ត៌មាន Fresh News សហការជាមួយក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ ក្នុងសប្តាហ៍នេះសូមលើកយកប្រធានបទស្តីពី «ការសុំកូន» មកធ្វើការបកស្រាយដូចតទៅ៖**
**«ការសុំកូន» គឺជាការសុំកូនរបស់អ្នកដទៃមកចិញ្ចឹមដោយស្របច្បាប់ និងបង្កើតទំនាក់ទំនងញាតិរវាងពួកគេ ពោលគឺធ្វើឲ្យទំនាក់ទំនងញាតិរវាងឪពុកម្តាយចិញ្ចឹម និងកូនចិញ្ចឹម ដូចគ្នាទៅនឹងឪពុកម្តាយនិងកូនបង្កើតដែរ ។ គោលបំណងនៃការសុំកូនគឺធ្វើឡើងសម្រាប់៖**

* អ្នកដែលគ្មានទាយាទស្នងអាជីវកម្ម ត្រូវរកទាយាទស្នងបានតាមរយៈការសុំកូន
* អ្នកដែលគ្មានទាយាទស្នងមរតក ឬសន្តតិកម្មទ្រព្យសម្បត្តិជាអាទិ៍ ត្រូវរកទាយាទស្នងបានតាមរយៈការសុំកូន
* អ្នកដែលអសមត្ថភាពគ្មានកូន ត្រូវការកូនដើម្បីអាចផ្តល់អាហារកិច្ច ឬមើលថែខ្លួននៅពេលចាស់ទៅ
* រកឪពុកម្តាយសម្រាប់កុមារកំព្រា ឬកុមារដែលខ្វះការថែរក្សា ឬការយកចិត្តទុកដាក់ពីឪពុកម្តាយបង្កើត......។ល។

អនុលោមតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន បានបើកផ្លូវដល់អ្នកដែលមានបំណង "សុំកូន" ឬ "សុំកូនគេមកចិញ្ចឹមដោយស្របច្បាប់" អាចធ្វើឡើងតាមរូបភាព ០២ (ពីរ) គឺ៖ (១).ការសុំកូនពេញលេញ និង (២).ការសុំកូនធម្មតា។

(១)៖ ការសុំកូនពេញលេញ៖ គឺជាការសុំកូនរបស់អ្នកដទៃយកមកចញ្ចឹមដោយស្របច្បាប់ និងធ្វើឡើងតាមផ្លូវតុលាការ ដោយទាមទារឲ្យផ្តាច់ទំនាក់ទំនងញាតិ និងទំនាក់ទំនងគតិយុត្តិ រវាងឪពុកម្តាយបង្កើត និងញាតិសន្តានរបស់កូនសុំនោះទាំងស្រុង ដើម្បីបង្កើតឲ្យមាននូវទំនាក់ទំនងញាតិ និងទំនាក់ទំនងគតិយុត្ត រវាងឪពុកម្តា

យចិញ្ចឹម និងកូនសុំនោះវិញ។ ការណ៍ដែលធ្វើបែបនេះ គឺដើម្បីឲ្យទំនាក់ទំនងរបស់ឪពុកម្តាយចិញ្ចឹម និងកូនសុំនោះ ដូចគ្នាទៅនឹងទំនាក់ទំនងឪពុកម្តាយ និងកូនបង្កើតដែលច្បាប់បានទទួលស្គាល់ ។ គោលបំណងនៃការសុំកូនពេញលេញខាងលើនេះ គឺធ្វើឡើងដើម្បីផ្តល់នូវគ្រួសារមួយ ដែលមានឪពុកម្តាយមានជីវភាពសមរម្យ និងអាចផ្គត់ផ្គង់គ្រប់គ្រាន់ដល់កុមារអភ័ព្វ (កូនសុំ) និងដើម្បីផលប្រយោជន៍កុមារដែលខ្វះការថែរក្សា ខ្វះការយកចិត្តទុកដាក់ពីឪពុកម្តាយបង្កើត ឬឪពុកម្តាយបង្កើតមានជីវភាពក្រីក្រ ពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការមើលថែរក្សាកូនបាន ឬដោយសារស្ថានភាពណាមួយ ដូចជាបញ្ហាវិបត្តិស្មារតី ឬ ពិការភាពជាដើម.....។ **ខាងក្រោមនេះជាលក្ខខណ្ឌដើម្បីសុំកូនពេញលេញ៖**

* ឪពុក-ម្តាយចិញ្ចឹម ត្រូវតែមានសហព័ទ្ធ(ប្តី/ប្រពន្ធស្របច្បាប់) និងត្រូវមានឆន្ទះព្រមព្រៀងគ្នាក្នុងការសុំកូន

* ឪពុក¬-ម្តាយចិញ្ចឹម ត្រូវមានអាយុចាប់ពី ២៥ ឆ្នាំឡើងទៅ ហើយត្រូវមានអាយុច្រើនជាង "កូនសុំ" យ៉ាងតិច ២០ឆ្នាំ

* ជាគោលការណ៍ "កូនសុំ" ត្រូវតែជាអនីតិជន ដែលមានអាយុតិចជាង ៨ឆ្នាំ

* ត្រូវមានការយល់ព្រមពីឪពុកម្តាយបង្កើត ឬ អាណាព្យាបាលរបស់ «កូនសុំ» ប៉ុន្តែប្រសិនបើឪពុកម្តាយបង្កើតមិនអាចបង្ហាញឆន្ទះបាន ឬ ករណីដែលឪពុកម្តាយបង្កើតនោះបានបោះបង់កូនចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀត ដែលបំពានផលប្រយោជន៍កុមារដែលនឹងក្លាយជាកូនសុំនោះ គឺមិនចាំបាច់មានការយល់ព្រមពីឪពុកម្តាយបង្កើតរបស់ «កូនសុំ» នោះឡើយ។

* មូលហេតុនៃការសុំកូនពេញលេញ ត្រូវតែនៅក្នុងករណីដែលស្ថានភាពរបស់កុមារ (កូនសុំ) មានការពិបាកខ្លាំង និងបានជាប្រយោជន៍របស់កុមារដែលនឹងក្លាយជាកូនសុំនោះ ។

* ការសាកល្បងចិញ្ចឹមកុមារដែលនឹងក្លាយជាកូនសុំនោះ រយៈពេល ០៦ (ប្រាំមួយ) ខែ ដើម្បីជាមូលដ្ឋានក្នុងការសម្រេចសេចក្តីរបស់តុលាការ ។

បន្ទាប់ពីមានលក្ខខណ្ឌដូចរៀបរាប់ខាងលើនេះហើយ ឪពុក-ម្តាយចិញ្ចឹម ត្រូវតែមានឆន្ទៈសហការគ្នា និងព្រមព្រៀងដាក់ពាក្យសុំទៅកាន់តុលាការនៃទីលំនៅរបស់ឪពុកម្តាយចិញ្ចឹមនោះ ដើម្បីឲ្យតុលាការចេញដីកាសម្រេចបង្កើតសុំកូនពេញលេញ ។

(២)៖ ការសុំកូនធម្មតា៖ គឺជាការបង្កើតទំនាក់ទំនងញាតិរវាងកូនអ្នកដទៃ និងឪពុកម្តាយចិញ្ចឹមដែលបានសុំកូនអ្នកដទៃនោះយកមកចិញ្ចឹមបីបាច់ថែរក្សាដូចជាកូនរបស់ខ្លួនឯង បង្កើតតាមផ្លូវតុលាការ ប៉ុន្តែការសុំកូនធម្មតានេះមិនបានធ្វើឲ្យផ្តាច់ទំនាក់ទំនងញាតិរវាងឪពុកម្តាយបង្កើត និងកូនសុំនោះទេ ពោលគឺទំនាក់ទំនងញាតិរបស់ពួកគេនៅតែបន្តអត្ថិភាព នាំឲ្យពួកគេមានសិទ្ធិទាមទារ និងករណីយកិច្ចផ្គត់ផ្គង់អាហារកិច្ចគ្នាទៅវិញទៅមក ។ ជាងនេះទៅទៀតកូនសុំនោះនៅតែជាសន្តតិជន (ទាយាទ) មានសិទ្ធិទទួលបានមរតក់ របស់ឪពុកម្តាយបង្កើតរបស់គេដដែល ។ **ទន្ទឹមនឹងនេះកូនសុំក៏មានសិទ្ធិទទួលសន្តតិកម្មពីឪពុកម្តាយចិញ្ចឹមផងដែរ។ ខាងក្រោមនេះជាលក្ខខណ្ឌដើម្បីសុំកូនធម្មតា៖**

* ឪពុកម្តាយចិញ្ចឹម អាចនៅលីវ ឬមានសហព័ទ្ធ (ប្តី-ប្រពន្ធស្របច្បាប់)

* ឪពុក-ម្តាយចិញ្ចឹម ត្រូវមានអាយុចាប់ពី ២៥ ឆ្នាំឡើងទៅ

* កូនសុំ អាចជាអនីតិជន ឬ នីតិជន ប៉ុន្តែមិនត្រូវជាបុព្វញាតិ ឬ មានអាយុច្រើនជាងឪពុក-ម្តាយចិញ្ចឹមឡើយ

* កូនសុំ ជាអនីតិជន ត្រូវមានការយល់ព្រមពីឪពុក/ម្តាយបង្កើត ឬអ្នកមានអំណាចមេបា ឬអាណាព្យាបាល ។

បន្ទាប់ពីមានលក្ខខណ្ឌដូចរៀបរាប់ខាងលើនេះហើយ ឪពុក-ម្តាយចិញ្ចឹម និងកូនសុំ ត្រូវមានឆន្ទៈដូចគ្នា និងព្រមព្រៀងដាក់ពាក្យសុំជាមួយគ្នា ទៅកាន់តុលាការនៃទីលំនៅរបស់ កូនសុំនោះដើម្បីឲ្យតុលាការចេញដីកាសម្រេចបង្កើតសុំកូនធម្មតា។ ប៉ុន្តែបើកូនសុំជាអនីតិជន ឪពុក-ម្តាយចិញ្ចឹមត្រូវដាក់ពាក្យសុំជាមួយអ្នកមានអំណាចមេបា ឬ អាណាព្យាបាល នៃកូនសុំនោះ ទៅកាន់តុលាការនៃទីលំនៅរបស់កូនសុំ។ អ្នកដាក់ពាក្យសុំមិនចាំបាច់ត្រូវតែជាអ្នកមានសហព័ទ្ធ (ប្តី-ប្រពន្ធស្របច្បាប់) នោះទេ ពោលគឺបុរស ឬនារីដែលនៅលីវ ក៏អាចក្លាយជាឪពុក ឬ ម្តាយចិញ្ចឹម

បានដែរ ប៉ុន្តែចំពោះអ្នកមានសហព័ទ្ធ (ប្តី-ប្រពន្ធស្របច្បាប់) ប្រសិនបើមានតែសហព័ទ្ធម្ខាងដែលចង់បានកូនចិញ្ចឹមនោះ អានុភាពមានតែចំពោះតែអ្នកដែលបានដាក់ពាក្យសុំតែប៉ុណ្ណោះ។

យ៉ាងណាមិញការសុំកូនអ្នកដទៃយកមកចិញ្ចឹមដោយស្របច្បាប់ ដែលយើងហៅថាការសុំកូននេះ ត្រូវតែធ្វើឡើងតាមផ្លូវតុលាការ ដូច្នេះការដែលចង់រំលាយការសុំកូននេះវិញ ក៏ត្រូវធ្វើឡើងតាមរយៈការកាត់កាលតាមផ្លូវតុលាការ ដូចគ្នាផងដែរ។

សូមបញ្ជាក់ផងដែរថាចំពោះជនបរទេស ដែលមានបំណងសុំកុមារកម្ពុជាទៅចិញ្ចឹម គឺត្រូវបំពេញតាមលក្ខខណ្ឌដោយឡែក (ច្បាប់ស្តីពីសុំកូនអន្តរប្រទេស)។

រៀបរៀងដោយ៖ លោកមេធាវី ឡាន ស៊ីនីត និងកញ្ញា សារី លីដា សមាជិកក្រុមការងាររៀបចំ និងផ្សព្វផ្សាយអត្ថបទច្បាប់ នៃក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ។

## ពលករខ្មែរជួបគ្រោះថ្នាក់ចរាចរណ៍ស្លាប់2នាក់ប្តីប្រពន្ធកាលពីថ្ងៃទី8ខែកញ្ញាឆ្នាំ2018នៅឃុំភេ ខេត្តរ៉ាក់យ៉ង កន្លងទៅ

https://www.facebook.com/profile.php កម្មករ ឆ្លងដែន 16-09-2018

ពលករខ្មែរដែលបានជួបគ្រោះថ្នាក់ចរាចរណ៍ស្លាប់2នាក់ប្តីប្រពន្ធកាលពីថ្ងៃទី8 ខែកញ្ញា ឆ្នាំ2018 នៅឃុំភេ ខេត្តរ៉ាក់យ៉ង កន្លងទៅ។ ក្រុមការងារទីប្រឹក្សាទទួលបន្ទុកពលករប្រចាំប្រទេសថៃ បានចុះសួរសុខទុក្ខនិងចូលរួមរំលែកទុក្ខដល់សាច់ញាតិសពកាលពីថ្ងៃទី13ខែកញ្ញាឆ្នាំ2018 នៅវត្តភេត្រាសុខារុម ស្ថិតនៅក្នុងឃុំភេ ស្រុកមឿង ខេត្តរ៉ាក់យ៉ង។ ពលករដែលបានស្លាប់បាត់បង់ជីវិតមានឈ្មោះ គុត សុណា ភេទប្រុស អាយុ25ឆ្នាំត្រូវជាប្តី និងប្រពន្ធឈ្មោះ ញ៉ង់ ជារ៉ា ភេទស្រី អាយុ24ឆ្នាំ មានស្រុកកំណើតនៅ ភូមិជ័យនិគមន៍ ឃុំកណ្តាលជ្រុំ ស្រុកពញាក្រែក ខេត្តកំពង់ចាម។

## រដ្ឋាភិបាលថៃ គ្រោងកម្ទេចទូកខុសច្បាប់ជិត ៩០០គ្រឿង

http://kleykley.sabay.com.kh/article/ ថ្ងៃនេះ ១៧ កញ្ញា ២០១៨ ម៉ោង 11:41

ទូកសរុបចំនួន ៨៦១គ្រឿង ដែលពុំបានចុះបញ្ជី គ្រោងនឹងត្រូវកម្ទេចចោលនៅពាក់កណ្តាលខែធ្នូ ២០១៨ ខាងមុខ។ នេះបើតាមការបញ្ជាក់របស់លោក Chirute Visalachitra អគ្គនាយក នៃនាយកដ្ឋានម៉ារីន នៃក្រសួងដឹកជញ្ជូនថៃ។ ការកម្ទេចនេះ គឺជាកិច្ចខិតខំដើម្បីធ្វើឲ្យប្រសើរឡើងនូវមុខមាត់នៃទូកនេសាទថៃ និងការប្រឆាំងនឹងការនេសាទខុសច្បាប់ មុនរដ្ឋាភិបាលថៃចូលរួមកិច្ចពិភាក្សាជុំបន្ទាប់ជាមួយសហភាពអឺរ៉ុប ស្តីពីការនេសាទខុសច្បាប់ គ្មានការរាយការណ៍ និងផ្ទុយបទប្បញ្ញ ដែលនឹងធ្វើឡើងនៅខែកញ្ញា ២០១៨នេះ។ តាមការចុះផ្សាយរបស់ Bangkok Post បញ្ជាក់ថា គិតត្រឹមថ្ងៃទី១៦ ខែកញ្ញា ២០១៨ មានទូកនេសាទចំនួន ១០៧៤៣គ្រឿងបានចុះបញ្ជីរួចរាល់ ខណៈ ៦៣១៥គ្រឿងទៀត មិនទាន់ចុះបញ្ជីរួចរាល់នោះទេ។ សូមបញ្ជាក់ថា ប្រទេសថៃត្រូវបានសហភាពអឺរ៉ុបពិន័យកាតលឿង សម្រាប់ការគ្រប់គ្រងនាវានេសាទមិនបានត្រឹមត្រូវ។ ប្រភព៖ Bangkokpost ប្រែសម្រួល៖ វាសនា

## គួរឲ្យសរសើរសមត្ថកិច្ចវៀតណាមណាស់ គ្រាន់តែពលរដ្ឋខ្មែរឆ្លងដែនទៅលក់ឆ្នោត ក៏ចាប់បញ្ជូនមកវិញភ្លាមៗមិនទុកយូរទេ

http://isharetoday.com/archives/ POSTED BYBRID DONSEPTEMBER 15, 2018

ស្វាយរៀងៈ មនុស្សក្មេងចាស់ប្រុសស្រីចំនួន៣១នាក់ ត្រូវបានសមត្ថកិច្ចវៀតណាមចាប់បញ្ជូនមកប្រគល់ជូនការិយាល័យប្រឆាំងការជួញដូរមនុស្ស កាលពីថ្ងៃសុក្រ ៥កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៨ ខណៈដែលពួកគេឆ្លងដែនចូលទៅដោយខុសច្បាប់។ ពលរដ្ឋទាំងអស់នេះ ត្រូវបានខាងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយមន្ទីរ សង្គមកិច្ចខេត្ត កម្លាំងអធិការដ្ឋាននគរបាលក្រុងបាវិត និងកម្លាំងអធិការ ដ្ឋាននគរបាលស្រុកកំពង់រោទិ៍ កម្លាំងអធិការដ្ឋាននគរបាលស្រុកចន្ទ្រា និងអាជ្ញាធរមូលដ្ឋាន បានទទួលប្រជាពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់។

បើតាមមន្ត្រីនៅទីនោះបញ្ជាក់ថា ពលរដ្ឋខ្មែរទាំងនេះ លួចឆ្លងដែនទៅរកការងារធ្វើ និងលក់ឆ្នោតនៅប្រទេសវៀតណាម ដែលត្រូវភាគីវៀតណាម ចាប់បញ្ជូនមកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិបាវិត ចំនួន១លើក មានចំនួន១៦គ្រួសារ មនុស្សរួមចំនួន ៣១នាក់ ស្រី២០នាក់ ក្នុងនោះមនុស្សចាស់ចំនួន៧នាក់ស្រី កុមារចំនួន២៤នាក់ កុមារីចំនួន១៣នាក់ បានធ្វើការអប់រំ និងធ្វើកិច្ចសន្យាចំពោះ មនុស្សចាស់ចំនួន៧នាក់ស្រី មិនអោយធ្វើចំណាកស្រុកខុសច្បាប់តទៅទៀត។ សមត្ថកិច្ចភាគីកម្ពុជា បានប្រគល់ប្រជាពលរដ្ឋទាំង១៦ គ្រួសារឲ្យមន្ទីរសង្គមកិច្ចខេត្ត ដើម្បីយកទៅមូលដ្ឋានរៀងៗខ្លួនវិញ៕

## ស្ថានតំណាងកម្ពុជានៅក្រៅប្រទេស ធ្វើអន្តរាគមន៍ជួយពលរដ្ឋខ្មែរចំនួន៥៥នាក់

http://cambodiapolice.com/policekh/ 9:59 am 17 កញ្ញា 2018 33

**ភ្នំពេញ៖** ស្ថានតំណាងកម្ពុជានៅក្រៅប្រទេស ធ្វើអន្តរាគមន៍ជួយពលរដ្ឋខ្មែរចំនួន៥៥នាក់៖

១.ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសចិន បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ ចិន ធ្វើអន្តរាគមន៍ជួយសង្គ្រោះ និងរៀបចំមាតុភូមិនិវត្តន៍ស្ត្រីខ្មែរចំនួន២នាក់ មកពីខេត្តកំពង់ចាម និងត្បូងឃ្មុំ ដែលត្រូវបានមេខ្យល់បោកបញ្ឆោតនាំទៅរៀបការដោយខុសច្បាប់ជាមួយបុរសជនជាតិចិននៅក្នុងប្រទេសចិន។ ស្ត្រីទាំងពីរនាក់ បានត្រលប់មកដល់កម្ពុជាវិញ នៅរសៀលថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៨ ។

២.ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ម៉ាឡេស៊ី រៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរចំនួន២២នាក់ មកពីខេត្តកំពង់ចាម កំពង់ធំ តាកែវ ត្បូងឃ្មុំ បាត់ដំបង ពោធិ៍សាត់ ព្រះវិហារ និងខេត្តស្វាយរៀង ដែលបានទៅធ្វើការដោយខុសច្បាប់នៅប្រទេសម៉ាឡេស៊ី ហើយមានបំណងត្រលប់មកកម្ពុជាវិញ។ ពលករ-ពលការិនីទាំង២២នាក់ បានមកដល់កម្ពុជា នៅព្រឹកថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៨។

៣.ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងហូជីមិញ បានសហការជាមួយអាជ្ញាធរវៀតណាម រៀបចំមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរចំនួន៣១នាក់(ក្នុងនោះមានកុមារ២៣នាក់) មកពីខេត្តស្វាយរៀង ដែលចូលទៅស្នាក់នៅ និងប្រកបរបរលក់ឆ្នោតដោយខុសច្បាប់នៅក្នុងប្រទេសវៀតណាម។ ស្ថានអគ្គកុងស៊ុល បានជូនពលរដ្ឋទាំង៣១នាក់នោះ មកដល់កម្ពុជាវិញ នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៨ តាមច្រកទ្វារព្រំដែនអន្តរជាតិបាវិត ដើម្បីប្រគល់ជូនអាជ្ញាធរកម្ពុជា ចាត់ចែងបញ្ជូនបន្តទៅស្រុកកំណើត ៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

# ស្ថានតំណាងកម្ពុជានៅក្រៅប្រទេស ធ្វើអន្តរាគមន៍ជួយពលរដ្ឋខ្មែរចំនួន៥៥នាក់

-----------

១. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ចិន** បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ចិន ធ្វើអន្តរាគមន៍ជួយសង្គ្រោះ និងរៀបចំមាតុភូមិនិវត្តន៍ស្ត្រីខ្មែរចំនួន**២នាក់** មកពីខេត្តកំពង់ចាម និងត្បូងឃ្មុំ ដែលត្រូវបានមេខ្យល់បោកបញ្ឆោតនាំទៅរៀបការដោយខុសច្បាប់ជាមួយបុរសជនជាតិចិននៅក្នុងប្រទេសចិន។ ស្ត្រីទាំងពីរនាក់ បានត្រលប់មកដល់កម្ពុជាវិញ នៅរសៀលថ្ងៃទី**១៦** ខែ **កញ្ញា** ឆ្នាំ**២០១៨** ។

២. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ម៉ាឡេស៊ី រៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរចំនួន**២២នាក់** មកពីខេត្តកំពង់ចាម កំពង់ធំ តាកែវ ត្បូងឃ្មុំ បាត់ដំបង ពោធិ៍សាត់ ព្រះវិហារ និងខេត្តស្វាយរៀង ដែលបានទៅធ្វើការដោយខុសច្បាប់នៅប្រទេសម៉ាឡេស៊ី ហើយមានបំណងត្រលប់មកកម្ពុជាវិញ។ ពលករ-ពលការិនីទាំង២២នាក់ បានមកដល់កម្ពុជា នៅព្រឹកថ្ងៃទី**០២** ខែ **កញ្ញា** ឆ្នាំ **២០១៨** ។

៣. ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុង**ហូជីមិញ** បានសហការជាមួយអាជ្ញាធរវៀតណាម រៀបចំមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរចំនួន**៣១នាក់** (ក្នុងនោះមានកុមារ២៣នាក់) មកពីខេត្តស្វាយរៀង ដែលចូលទៅស្នាក់នៅនិងប្រកបរបរលក់ឆ្នោតដោយខុសច្បាប់នៅក្នុងប្រទេសវៀតណាម។ ស្ថានអគ្គកុងស៊ុលបានជូនពលរដ្ឋទាំង៣១នាក់នោះ មកដល់កម្ពុជាវិញ នៅថ្ងៃទី**១៤** ខែ **កញ្ញា** ឆ្នាំ **២០១៨** តាមច្រកទ្វារព្រំដែនអន្តរជាតិ**បាវិត** ដើម្បីប្រគល់ជូនអាជ្ញាធរកម្ពុជា ចាត់ចែងបញ្ជូនបន្តទៅស្រុកកំណើត។

ថ្ងៃ ចន្ទ ៨កើត ខែ ភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ភ្នំពេញ ថ្ងៃទី១៧ ខែ កញ្ញា ឆ្នាំ ២០១៨

**គេត សោផាន់**

**អ្នកនាំពាក្យ**

**ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

# ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨

## អាសូរជីវិតពលករខ្មែរ! ព្រួតគ្នាវាយរហូតដល់ស្លាប់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៨ ម៉ោង ០៩:៥៨ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ ពលករខ្មែរម្នាក់ត្រូវជនដៃដល់ជាជនជាតិថៃមួយក្រុមជិះម៉ូតូតាមព្រួតវាយរងរបួសធ្ងន់ ពេលជនរងគ្រោះវិលត្រឡប់ពីធ្វើការ បន្ទាប់មកជនរងគ្រោះក៏បានស្លាប់នៅក្នុងមន្ទីរពេទ្យ។ ហេតុការណ៍ខាងលើកើតឡើងនៅខេត្តឈុនបុរី ប្រទេសថៃ កាលពីម៉ោង១០យប់ថ្ងៃទី១៥ កញ្ញា ២០១៨។ ជនរងគ្រោះ ឈ្មោះឡាំ កក្ដា ហៅពេទ្យ ភេទប្រុស អាយុ៣២ឆ្នាំ ជាជាង មានស្រុកកំណើត នៅភូមិឃីឡែក ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ។

តាមសាច់ញាតិជនរងគ្រោះបានប្រាប់ថា ជនរងគ្រោះត្រូវមនុស្សមួយក្រុមជិះម៉ូតូតាមព្រួតវាយ បណ្ដាលឲ្យរបួសធ្ងន់ ពេលជនរងគ្រោះកំពុងជិះម៉ូតូវិលត្រឡប់ពីធ្វើការ ដោយពុំដឹងពីមូលហេតុ កាលពីវេលាម៉ោងប្រហែល១០យប់ថ្ងៃទី១៥ កញ្ញា ។ សាច់ញាតិជនរងគ្រោះបានបន្តថា ក្នុងហេតុការណ៍នោះដែរ ជនរងគ្រោះដែលរងរបួសធ្ងន់ត្រូវបានគេបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យក្នុងស្រុកកើតហេតុ បន្ទាប់មកក៏បានស្លាប់នៅម៉ោង៧ព្រឹកថ្ងៃទី១៦ កញ្ញា និងត្រូវភាគីថៃបញ្ជូនសពមកកម្ពុជាតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ដើម្បីប្រគល់សពឲ្យសាច់ញាតិនាយប់ថ្ងៃទី១៧ កញ្ញា ២០១៨នេះ។ បើតាមសាច់ញាតិជនរងគ្រោះប្រាប់ថា ក្រុមជនសង្ស័យក្នុងអំពើឃាតកម្មខាងលើត្រូវបានសមត្ថកិច្ចថៃធ្វើការឃាត់ខ្លួនហើយគឺជាជនជាតិថៃចំនួន៣នាក់ ប៉ុន្តែគេនៅមិនទាន់ដឹងពីមូលហេតុនៅឡើយទេ។

សពត្រូវបានសាច់ញាតិជួលរថយន្តដឹកបន្តពីលើស្ពានមិត្តភាពកម្ពុជាថៃនៃច្រកទ្វារអន្តរជាតិប៉ោយប៉ែតខ្លងលឹកទៅកាន់លំនៅដ្ឋានដើម្បីធ្វើបុណ្យតាមប្រពៃណី៕

## ថៃកំពុងត្រូវការពលករបន្ថែមសម្រាប់បម្រើការក្នុងវិស័យនេសាទ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៨ ម៉ោង ១១:១៩ ណៃ ដាលីន

ទីក្រុងបាងកក ៖ ក្នុងពេលថ្មីៗនៃក្រសួងការងារថៃបានសម្រេចជួលពលករអន្តោប្រវេសន៍បន្ថែមតាមរយៈអនុស្សរណៈនៃការយោគយល់គ្នា (MoU) ។ វាជាកត្តាជំរុញមួយដល់វិស័យនេសាទរបស់ប្រទេសថៃដែលបានជួបប្រទះបញ្ហាកង្វះពលកម្ម ។ តាំងពីរដ្ឋាភិបាលចេញវិធានការលើពលករអន្តោប្រវេសន៍ខុសច្បាប់មក ចំនួនពលករអន្តោប្រវេសន៍ក្នុងវិស័យនេសាទបានធ្លាក់ចុះពី១១ម៉ឺននាក់មកស្មើ៥ម៉ឺននាក់ប៉ុណ្ណោះ ។ ការជួលពលករក្រោមប្រព័ន្ធ MoUគឺជាវិធានការមួយក្នុងចំណោមវិធានការទាំង៣ដែលក្រសួងបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហាកង្វះពលកម្ម ។ វិធានការពីរទៀតរួមមាន ការពន្យារពេលសុពលភាពនៃប័ណ្ណអនុញ្ញាតការងារប្រមាណ២ឆ្នាំ សម្រាប់ពលករអន្តោប្រវេសន៍១,១ម៉ឺននាក់ ដែលមានប័ណ្ណការងារពួកគេនឹងផុតសុពលភាពនៅចុងខែនេះ ខណៈដែលវិធានការមួយទៀតគឺអនុញ្ញាតឲ្យពលករអន្តោប្រវេសន៍ដែលមានលិខិតឆ្លងដែន អត្តសញ្ញាណប័ណ្ណ ឬឯកសារធ្វើដំណើរផ្សេងៗឲ្យចុះឈ្មោះធ្វើការក្នុងវិស័យនេសាទក្នុងរយៈពេល១ឆ្នាំ ។

បញ្ហាកង្វះពលកម្មនេះជាលទ្ធផលនៃការរឹតបន្តឹងរបស់រដ្ឋាភិបាល លើការគ្រប់គ្រងពលករអន្តោប្រវេសន៍ និងការជួញដូរមនុស្ស ដែលជាផ្នែកមួយក្នុងការដោះស្រាយបញ្ហានេសាទដែលខុសច្បាប់ មិនរាយការណ៍ និងមិនស្ថិតក្រោមការគ្រប់គ្រង។ ក្រសួងការងារថៃចង់ឲ្យពលករអន្តោប្រវេសន៍ចូលមកកាន់ប្រទេសខ្លួនតាមប្រព័ន្ធMoU ព្រោះវិធានការនេះធានាថាពលករបរទេសត្រូវបានត្រួតពិនិត្យដោយភ្នាក់ងាររដ្ឋប៉ុន្តែប្រព័ន្ធនេះមិនដែលជោគជ័យទេ

ព្រោះតែការដាក់សម្ពាធពីអាជីវករ ។ អាជីវករក្នុងវិស័យនេះចង់ឲ្យរដ្ឋាភិបាលអនុញ្ញាតឲ្យពលករអន្តោប្រវេសន៍ចុះឈ្មោះចូលមកធ្វើការបានគ្រប់ពេល ព្រោះពួកគេអះអាងថា ពលករនេសាទភាគច្រើនបោះបង់ការងារចោលភ្លាមៗ ធ្វើឲ្យពួកគេត្រូវស្វែងរកពលករថ្មី។ ដោយហេតុដូចនេះ អាជីវករខាងលើតែងតែងាកទៅរកជនអន្តោប្រវេសន៍ខុសច្បាប់ទៅវិញ ។

យោងតាមអ្នកនាំពាក្យរបស់រដ្ឋាភិបាលលោក Sansern Kawekamnerd បាននិយាយកាលពីថ្ងៃទី៩ កញ្ញា ថា លោកនាយករដ្ឋមន្ត្រី Prayut Chan-o-cha បានផ្តល់គោលការណ៍ណែនាំដល់សមត្ថកិច្ចដើម្បីដោះស្រាយបញ្ហាកង្វះពលករក្នុងវិស័យនេសាទ ។ លោក Sensern បាននិយាយថា យោងតាមលោកនាយករដ្ឋមន្ត្រី បញ្ហានេះត្រូវតែដោះស្រាយភ្លាមៗ ព្រោះប្រទេសថៃស្ថិតក្នុងចំណោមប្រទេសនាំមុខក្នុងវិស័យនេសាទលើពិភពលោក ដែលទទួលបានប្រាក់ចំណូលជាច្រើនពីវិស័យនេះ ។ លោកបានបន្តថា ព្រោះតែក្នុងពេលបច្ចុប្បន្ននេះប្រទេសថៃត្រូវការពលករប្រមាណ៥,៣ម៉ឺននាក់ក្នុងវិស័យនេសាទ ប្រទេសនេះត្រូវតែពឹងផ្អែកលើពលករដែលមកពីប្រទេសជិតខាង ព្រោះប្រជាជនថៃមិនចាប់អារម្មណ៍នឹងការងារដូច្នេះឡើយ ។ អ្នកនាំពាក្យរូបនេះបានបន្ថែមថា លោកនាយករដ្ឋមន្ត្រីបានផ្តល់ជម្រើស៣ក្នុងគោលការណ៍ណែនាំរបស់លោក។ ជម្រើសទី១ គឺឲ្យប្រទេសថៃបន្លាយពេលសុពលភាពនៃសាលិខិតអនុញ្ញាតការងាររបស់ពលករអន្តោប្រវេសន៍ដែលកំពុងតែធ្វើការក្នុងវិស័យនេះ។

ជម្រើសទី២ គឺឲ្យប្រទេសថៃទទួលយកពលករបន្ថែមពីប្រទេសមីយ៉ាន់ម៉ា កម្ពុជា និងឡាវ ខណៈជម្រើសទី៣គឺប្រទេសថៃអនុញ្ញាតឲ្យពលករអន្តោប្រវេសន៍ដែលធ្វើការក្នុងវិស័យដទៃដែលនៅក្នុងប្រទេសថៃដាក់ពាក្យធ្វើការក្នុងវិស័យនេសាទវិញ ។ ប្រទេសថៃ មានពលករអន្តោប្រវេសន៍ប្រមាណ១,១ម៉ឺននាក់ទៅហើយក្នុងវិស័យនេសាទដែលមានសាលិខិតអនុញ្ញាតការងារផុតសុពលភាពនៅថ្ងៃទី៣០ ខែកញ្ញា ខាងមុខនេះ ហើយសាលិខិតនេះអាចត្រូវបានពន្យារពេលបាន២ឆ្នាំទៀតរហូតដល់ឆ្នាំ ២០២០ ។ ជាមួយគ្នានេះផងដែរ ប្រទេសមីយ៉ាន់ម៉ាបានព្រមព្រៀងថានឹងផ្គត់ផ្គង់ពលករប្រមាណ ៤ម៉ឺននាក់ទៅកាន់ប្រទេសថៃផងដែរនៅចុងខែវិច្ឆិកាឆ្នាំនេះ ។ លើសពីនេះទៀត ពលករដែលធ្វើការក្នុង វិស័យដទៃដែលមានលិខិតឆ្លងដែនផ្លូវការ លិខិតឆ្លងដែនបណ្តោះអាសន្ន លិខិតបញ្ជាក់ និងលិខិតធ្វើដំណើរផ្សេងៗទៀតដែលនៅមានសុពលភាព អាចដាក់ពាក្យសុំធ្វើការក្នុងវិស័យនេសាទបានមួយឆ្នាំ ៕

## *ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨*

## តុលាការខេត្តសម្រេចឃុំខ្លួននារីម្នាក់ ពីបទ នាំចេញដោយមិនស្របច្បាប់

http://cambodiapolice.com/policekh/ 5:38 pm 18 កញ្ញា 2018

ខេត្តកំពង់ចាម ៖ ករណីនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ ដែលកម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយកម្លាំងអធិការដ្ឋាននគរបាលស្រុកចំការលើ បានបង្ក្រាបកាលពីថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨ ត្រូវបានលោក សួន សំណាង ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តកំពង់ចាម ចេញដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥១៣ ទ.ព្រ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨ ពីបទ នាំយកចេញដោយមិនស្របច្បាប់ ដោយមានគោលដៅ ប្រព្រឹត្តនៅភូមិប្រម៉ាត់ដី ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម កាលពីអំឡុងខែកុម្ភៈ និង ខែមីនា ឆ្នាំ២០១៨ ។

សូមរំលឹកផងដែរថាៈ កាលពីថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨ កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយកម្លាំងអធិការដ្ឋាននគរបាលស្រុកចំការលើ បានចុះអនុវត្តដីកាបញ្ជាឱ្យចូលខ្លួនលេខៈ ១៦៤០ ព.ស និង លេខៈ ១៦៤២ ព.ស ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨ របស់អយ្យការ អមសាលាដំបូងខេត្តកំពង់ចាម បញ្ជាឱ្យឈ្មោះ ផន សុខណេង ភេទស្រី អាយុ២១ឆ្នាំ ជនជាតិខ្មែរ នៅភូមិប្រម៉ាត់ដី ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម មកកាន់ស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម ដើម្បីសាកសួរបំភ្លឺ ពាក់ព័ន្ធ

ករណីនាំនារីខ្មែរទៅលក់ឱ្យបុរសជនជាតិចិននៅប្រទេសចិនធ្វើជាប្រពន្ធ។ ក្រោយពីសាកសួររួច សមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យឈ្មោះ ផន សុខណេង ដើម្បីកសាងសំណុំរឿងបញ្ជូនទៅអយ្យការ អមសាលាដំបូងខេត្តកំពង់ចាម ចាត់ការតាមនីតិវិធី។

បច្ចុប្បន្ន ជនជាប់ចោទ ត្រូវបានសមត្ថកិច្ចបញ្ជូនទៅឃុំខ្លួននៅពន្ធនាគារខេត្តកំពង់ចាម រួចរាល់ហើយ នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨ តាមបញ្ញត្តិច្បាប់ មាត្រា១០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ៕

## ឃីហោសុទ្ធតែហាងម៉ាស្សា តែមានអីលេខបង្កប់សេវាផ្លូវភេទ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៨ ម៉ោង ១១:២៥ ច័ន្ទ រស្មី

ខេត្តសៀមរាប ៖ តុលាការសម្រេចឃុំខ្លួនដែលជាថៅកែម៉ាស្សាប្រុសស្រី៣នាក់ ដាក់ពន្ធនាគារខេត្តបន្ទាប់ពីកម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានធ្មក់ ចូលបង្ក្រាបទីតាំងម៉ាស្សា២ផ្សេងគ្នា ក្នុងថ្ងៃតែមួយ ដែលបង្កប់សេវាផ្លូវភេទ និងរំដោះ បាននារីបម្រើការ នៅក្នុងហាងចំនួន៥នាក់ផងដែរ ព្រមទាំងធ្វើការបិតទីតាំងនោះជាបណ្តោះអាសន្ន ។

ចំណែកនារីរងគ្រោះដែលសុទ្ធសឹងជាអនីតិជន (ក្រោមអាយុ១៥ឆ្នាំ) ត្រូវបានធ្វើការប្រគល់ឱ្យទៅមន្ទីរសង្គមកិច្ចការងារខេត្ត ដើម្បីអប់រំកែប្រែ និងផ្តល់ជំនាញផ្សេងៗដល់ពួកគាត់ដែលពួកគាត់អាចទទួលយកបាន ។ ហេតុការណ៍នេះបានធ្វើឡើងកាល ពីយប់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៨ តាមបណ្តោយផ្លូវក្រវ៉ាត់ក្រុង ក្នុងភូមិត្រៀក សង្កាត់សៀមរាប ក្រុង-ខេត្តសៀមរាប ។

តាមប្រសាសន៍របស់លោកវរសេនីយ៍ឯកជា ហេង នាយការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្តបានប្រាប់ភ្នាក់ងារកោះសន្តិភាពឱ្យដឹងនៅវេលាម៉ោង៧និង៥៨នាទីព្រឹក ថ្ងៃទី១៩ ខែកញ្ញា នេះថា មុនពេលកើតហេតុកម្លាំងជំនាញបានចុះស្រាវជ្រាវរហូតឈាន់ដល់ធ្វើការឃាត់ខ្លួនបានថៅកែហាងម៉ាស្សាប្រុសស្រីចំនួន៣នាក់នៅទីតាំង២ផ្សេងគ្នា រួចនាំយកមកសួរនៅការិយាល័យជំនាញ ដើម្បីរៀបចំកសាងសំណុំរឿងបញ្ជូនទៅតុលាការខេត្ត ។ លោកបានបញ្ជាក់ថា ទីតាំងទី១- ឃាត់ខ្លួនបាន (ថៅកែម៉ាស្សា២នាក់ ប្តីប្រពន្ធទី១-ឈ្មោះ ថៃ នី ភេទស្រី អាយុ៣០ឆ្នាំ មានស្រុកកំណើតភូមិផ្គាំដូង ឃុំក្រូចឆ្មា ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម (ប្រពន្ធ) និងប្តីឈ្មោះ គឹម គន្ធា អាយុ៣៥ឆ្នាំ បច្ចុប្បន្នស្នាក់នៅផ្ទះជួល បើកហាងម៉ាស្សា ឃីហោ ៧៧៧៧ តាមបណ្តោយផ្លូវក្រវ៉ាត់ក្រុង ក្នុងភូមិត្រៀក សង្កាត់សៀមរាប ក្រុង-ខេត្តសៀមរាប ។ និងទីតាំងទី២-ឈ្មោះ ទុយ ស្រីមុំ ភេទស្រី អាយុ៣៧ឆ្នាំ ស្រុកកំណើតភូមិចុងឃ្នៀង សង្កាត់ចុងឃ្នៀស ក្រុង-ខេត្តសៀមរាប ដែលមានឃីហោ ៩៩៩ បច្ចុប្បន្នស្នាក់នៅភូមិត្រៀក សង្កាត់សៀមរាប ក្រុង-ខេត្តសៀមរាប ។ លោកបានបញ្ជាក់បន្ថែមថា ក្រោយឃាត់ខ្លួនថៅកែម៉ាស្សាចំនួន២ទីតាំងនៅកន្លែងផ្សេងគ្នា ក្នុងថ្ងៃតែមួយរួចមក កម្លាំងជំនាញយើងបានធ្វើការឆែកឆេររកឃើញជនរងគ្រោះជានារីចំនួន ៥នាក់ ដែលសុទ្ធសឹងជាអនីតិជន (ក្រោមអាយុ១៥ឆ្នាំ) ។ លោកបានបញ្ជាក់បន្ថែមទៀតថា ចំពោះនៅក្នុងក្រុងសៀមរាបមានហាងម៉ាស្សាសរុបទាំងអស់មានចំនួន៨២កន្លែង ហើយភាគច្រើន គឺពុំមានច្បាប់អនុញ្ញាតទេឱ្យតែគាត់មានលុយ គឺពួកគាត់តែងលើកស្លាកឃីហោដោយខ្លួនឯង ។ ក្នុងនោះមានថៅកែម៉ាស្សាជាជនជាតិវៀតណាមចំនួន៦កន្លែង គឺគ្មានច្បាប់ទាំងអស់ ។ លោកបន្ថែមទៀតថា ចំពោះហាងម៉ាស្សាដែលមិនមានច្បាប់ គឺលោកកំពុងរង់ចាំចំណាត់ការពីថ្នាក់លើថាត្រូវមានវិធានការយ៉ាងណា? ។

តាមប្រភពពីមន្ត្រីមន្ទីរសង្គមកិច្ចបានបញ្ជាក់ប្រាប់ នៅព្រឹកថ្ងៃទី១៩ ខែកញ្ញានេះថា រាល់បទល្មើសដែលសមត្ថកិច្ចប្រគល់ជនសង្ស័យមកឱ្យនោះ បើពួកគាត់ប្រើមនុស្សក្រោមអាយុ១៥ឆ្នាំ អនីតិជនហៅ (ជនរងគ្រោះ) គឺអាចឱ្យពួកគាត់ចូលរៀនវិញបានប្រសិនបើគាត់ចង់បន្តការសិក្សាតទៅទៀត ឬពួកគាត់ចង់រកជំនាញផ្សេងៗក៏បាន ។ ប្រភពបានបញ្ជាក់ថា ស្ត្រីដែលបានទទួលការអប់រំពីមន្ទីរសង្គមកិច្ចភាគច្រើនពេលត្រឡប់ទៅផ្ទះវិញ គាត់តែងតែប្តូរមុខរបរ ជារៀងរហូត គឺមិនចូលទៅធ្វើការជាអ្នកម៉ាស្សាបន្តទៀតទេ ។

គួរបញ្ជាក់ថា ពេលខ្លះពួកគាត់មិនបានឆ្លងកាត់ការអប់រំព្រមទាំងមានអ្នកទៅស្រុកកុហកនាំ មករកការងារធ្វើ បែរជានាំទៅធ្វើស្រីម៉ាស្សា ព្រោះពួកគាត់គ្មានជម្រើសដោយសារខ្លះឪពុកម្តាយបានយកលុយពីគេមុនក៏ថាបាន ? អ្នកខ្លះទៀតធ្វើអ្វីដែលខ្លួនចង់ អ្នកខ្លះមិនគួរធ្វើ ៕

## ក្មេងស្រីម្នាក់ត្រូវម្ដាយចុងធ្វើទារុណកម្មស្ទើរស្លាប់ រួចទុកចោលក្នុងព្រៃ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៨ ម៉ោង ២១:២២ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ នារីជាម្ដាយចុងម្នាក់ត្រូវនគរបាលការិយាល័យប្រឆាំងការជួញដូរ និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ធ្វើការឃាត់ខ្លួនពាក់ព័ន្ធនឹងករណីធ្វើទារុណកម្ម លើកូនដើមអាយុ៥ឆ្នាំ ស្ទើរស្លាប់ក្នុងព្រៃមួយកន្លែងនៅក្បែរផ្សាររុងក្លឿ ស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ ខណៈឪពុករវល់ទៅអូសរទេះ។ ជនសង្ស័យខាងលើឈ្មោះ លី ស្រីនីត អាយុ១៦ឆ្នាំ ជាកម្មករអូសរទេះស្នាក់នៅផ្សាររុងក្លឿទឹកដីថៃ និងមានទីលំនៅភូមិព្រៃព្រិច សង្កាត់ប៉ោយប៉ែត។ ជនសង្ស័យបានវាយធ្វើបាបក្មេងស្រីឈ្មោះ ណាត ស្រីមុី អាយុ៥ឆ្នាំ ឲ្យជាំមុខជាច្រើនកន្លែង និងស្នាមរបួសនៅត្រង់ក ហើយបបូរមាត់ទៀតផង។

ជួបសម្ភាសន៍ផ្ទាល់ជាមួយម្ដាយក្មេងរងគ្រោះឈ្មោះ យូ សុភី អាយុ២៤ឆ្នាំ មានទីលំនៅភូមិ និងសង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត ប្រាប់ថា នាងនិងកូនបានទៅស្នាក់នៅធ្វើការក្នុងខេត្តស្រះកែវ ហើយកាលពីព្រឹកថ្ងៃទី១៦ កញ្ញា ២០១៨ ម្ដាយឪពុករបស់នាងដែលធ្វើការនៅខេត្តស្រះកែវដែរនោះបានធ្វើដំណើរមកច្រកទ្វារអន្តរជាតិប៉ោយប៉ែតខ្លងលឹក ដើម្បីបន្តប័ណ្ណឆ្លងដែនស្នាក់នៅបន្តលើទឹកដីថៃ។ នាងបន្តថា ឪពុកម្ដាយនាងបានយកចៅ (ជនរងគ្រោះ) មកជាមួយលុះដល់ចំណុចផ្សាររុងក្លឿក៏ជួបនឹងអតីតប្តីរបស់នាង ដែលលែងលះគ្នា ហើយឈ្មោះ សុខ ឆាយ ស្រាប់តែគេសុំទុកកូនឲ្យនៅលេងជាមួយមួយរយៈ។ ដឹងអីក្រោយពីបុរសជាឪពុករវល់ទៅអូសរទេះបាត់នាងចុងអប្រិយក៏បាននាំកូននាងទៅក្នុងព្រៃខាងក្រោយផ្សារផល្លូចិន ក្បែរផ្សាររុងក្លឿង វាយធ្វើបាប និងមានស្នាមជាំពេញលើផ្ទៃមុខ និងស្នាមជាំក។ បញ្ហានេះគេសង្ស័យនាងចុងប៉ុនប៉ងសម្លាប់បំបិទមាត់ តែសំណាងហើយក្មេងនៅមានជីវិតក៏រត់ ចេញពីព្រៃត្រូវអាជីវករខ្មែរប្រទះឃើញនាំគ្នាថតបង្ហោះហ្វេសប៊ុកប្រកាសរកញាតិ បន្ទាប់មកដឹងដល់សមត្ថកិច្ចថក៏អន្តរាគមន៍ហៅរថយន្តសង្គ្រោះដឹកទៅព្យាបាលនៅមន្ទីរពេទ្យក្នុងស្រុកអារញ្ញតែម្តង។ ជីដូនជនរងគ្រោះឈ្មោះ ស៊ី សុផា អាយុ៤៨ឆ្នាំប្រាប់ថា នៅរសៀលថ្ងៃទី១៦ កញ្ញា ដោយទទួលទូរស័ព្ទពីអតីតកូនប្រសាឈ្មោះ សុខ ឆាយ ឪពុកក្មេងរងគ្រោះថាបាត់កូន គាត់ និងប្ដីក៏បានទាក់ទងប្ដឹងទៅសមត្ថកិច្ចថៃឲ្យជួយស្វែងរក។

ទីបំផុតបែជាសន្តិសុខផ្សាររុងក្លឿប្រាប់ពួកគាត់ថា មានក្មេងស្រីម្នាក់ត្រូវជួយដឹកទៅសង្គ្រោះនៅមន្ទីរពេទ្យ ពេលគាត់ និងប្ដីទៅរកមើលដឹងអីជាចៅស្រីសោះ។ លោកវរសេនីយ៍ត្រី អោក សំណុកនាយរងការិយាល័យប្រឆាំងការជួញដូរ និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលខេត្តប្រាប់ថាបន្ទាប់ពីឃើញក្មេងរងគ្រោះត្រូវបានគេបង្ហោះស្វែងរកសាច់ញាតិហើយថាត្រូវម្ដាយចុងធ្វើទារុណកម្មលោកក៏ទទួលបទបញ្ជាពីលោកឧត្តមសេនីយ៍ទោអាត់ ខែម ស្នងការនគរបាលខេត្ត ក៏ដូចជា នាយការិយាល័យចុះស្រាវជ្រាវសហការជាមួយអង្គការដៃគូរ ហូតបានជួបគ្រួសារ

រងគ្រោះ និងក្មេងរងគ្រោះសាកសួររកមូលហេតុ។ លោកនាយរងការិយាល័យបន្តថា ជនសង្ស័យក្រោយសួរនាំបានសារភាពថា នាងពិតជាបានធ្វើទារុណកម្មលើក្មេងរងគ្រោះខាងលើ ពិតប្រាកដមែន។

នាងរៀបរាប់ថា ដោយមានជម្លោះក្នុងគ្រួសារផងគាប់ជួនប្តីយកកូនដើមទៅលេង ឆ្លៀតឱកាសប្តីមិននៅនាងខឹងក៏នាំក្មេងស្រីខាងលើទៅក្នុងព្រៃខាងក្រោយផ្សាររុងត្លឿវាយធ្វើបាប និងយកស្មៅញ៉ុកមាត់នាងកុំឲ្យស្រែកឮដល់គេ។ ម្តាយចុងរូបនេះបន្តថា នាងបានយកដៃឆ្វេងច្របាច់ក ជនរងគ្រោះ និងទះមាត់ជាច្រើនដៃរហូតដួលសន្លប់ នាងក៏ទុកក្មេងនោះចោលនៅកន្លែងកើតហេតុ។ លុះបុរសជាប្តីវិលត្រឡប់ពីអូសរទេះនាងបានព្យាយាមកុហកថាបាត់កូនហើយ និងធ្វើជានាំប្តីដើររកកូនថែមទៀត។

ទីបំផុតស្រីចិត្តឃោរឃៅរូបនេះអស់លក្ខណ៍ត្រូវបែកការណ៍ ដោយសារបណ្តាញសង្គមគេបង្ហោះព្រោងព្រាត នាងក៏គេចពីផ្សាររុងត្លឿទៅរស់នៅក្នុងភូមិព្រៃព្រិច សង្កាត់ប៉ោយប៉ែត ហើយត្រូវសមត្ថកិច្ចជំនាញហៅសាកសួររហូតឈានដល់ការឃាត់ខ្លួន នៅព្រឹកថ្ងៃទី១៨ កញ្ញានេះ។ លោកវរសេនីយ៍ត្រី អោក សំណុក បញ្ជាក់ថា ជនសង្ស័យត្រូវបានឃាត់ខ្លួនតាមបទបញ្ជារបស់លោកព្រះរាជអាជ្ញាអមសាលាដំបូងខេត្តបន្ទាយមានជ័យហើយពេលនេះបានបញ្ជូនពីក្រុងប៉ោយប៉ែតទៅស្នងការដ្ឋាននគរបាលខេត្តដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់៕

## *ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨*

### ជនអន្តោរប្រវេសន៍ បញ្ជូនមកពីអាមេរិក ត្រូវចាប់ខ្លួននៅខ្មែរ ក្រោយចាប់បង្ខាំងសង្សារ ធ្វើទារុណកម្មផ្លូវភេទ និងគំរាមសម្លាប់ នៅភ្នំពេញ

http://www.arey-news.com/archives/ (ថ្ងៃទី 19 September 2018 ម៉ោង 9:24 pm)

**ភ្នំពេញ៖** នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ សមត្ថកិច្ចជំនាញនៃការិយាល័យស្រាវជ្រាវបទល្មើសជួញដូរមនុស្ស កងរាជអាវុធហត្ថរាជធានីភ្នំពេញ បានបញ្ជូនជនសង្ស័យ១នាក់ ទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីផ្តន្ទាទោសតាមនីតិវិធី ពាក់ព័ន្ធករណីហិង្សាគំរាមសម្លាប់ , បង្ខាំងទុក និង អំពើទារុណកម្ម ។ ជនសង្ស័យ ឈ្មោះ ព្រឿង សំអឿន ហៅសេម ភេទប្រុស អាយុ ៣៩ឆ្នាំ ធ្លាប់ជាអណិកជនរស់នៅសហរដ្ឋអាមេរិក អាចចាត់ទុកថា ជាជនកំណាចឃោរឃៅម្នាក់នៅកម្ពុជា ប្រចាំឆ្នាំ២០១៨ ដែលគួរឲ្យភ្ញាក់ផ្អើលបំផុត ដោយសមត្ថកិច្ចអាវុធហត្ថរាជធានីភ្នំពេញ ស្រាវជ្រាវឃើញថា ជននេះមានមុខរបរជាគ្រូបង្រៀនលំហាត់ប្រាណ នៅក្នុងក្លឹបស៊ុបភីហ្វីត បានប្រព្រឹត្តអំពើ បង្ខាំងទុកនារីម្នាក់ ប្រើអំពើហិង្សា និងធ្វើទារុណកម្មផ្លូវភេទ លើជនរងគ្រោះ ឈ្មោះ ម.ហ ភេទស្រី អាយុ ២២ឆ្នាំ ជានិស្សិតឆ្នាំទី២ ព្រមទាំងបានទូរស័ព្ទទៅក្រុមគ្រួសាររបស់ជនរងគ្រោះ ប្រើពាក្យសំដីមិនសមរម្យ ប៉ះពាល់ដល់កិត្តិយសជនរងគ្រោះ និងគំរាមបង្ហោះវីដេអូរួមភេទជាមួយគ្នាផងដែរ។

ជនសង្ស័យ បានសារភាពឲ្យដឹងថា រូបខ្លួន និងជនរងគ្រោះ បានស្គាល់គ្នារយៈពេល១ឆ្នាំមកហើយ ពួកគេទាំង ២នាក់ ស្គាល់ដំបូង គឺជនរងគ្រោះតែងមកហាត់ប្រាណនៅក្នុងក្លឹបស៊ុបភីហ្វីត រាល់ថ្ងៃ ហើយខ្លួនជាគ្រូបង្រៀនលំហាត់ប្រាណនៅទីនោះ ។ ក្រោយពេលពួកគេទាំង២នាក់ ស្គាល់គ្នាបានប្រហែល ៣សប្តាហ៍ ពួកគេទាំង២នាក់បានស្រឡាញ់គ្នាជាសង្សារ ហើយតែងតែទូរស័ព្ទណាត់ជួបគ្នា ដើម្បីរួមភេទជាញឹកញាប់ក្នុង១សប្តាហ៍ ២ទៅ ៣ដង ហើយក្នុងពេលរួមភេទម្តងៗ ជនសង្ស័យខាងលើ តែងតែ ថតជាវីដេអូទុកផងដែរ។ លើកដំបូង ពួកគេរួមភេទជាមួយគ្នាក្នុងផ្ទះសំណាក់ម្តុំផ្សារសុវណ្ណា ហើយក្រោយៗមកទៀត ពួកគេបានជួលបន្ទប់ខុនដូ មួយឈ្មោះ MHM បន្ទប់លេខ១៦៤ សង្កាត់ទួលទំពូង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ដើម្បីណាត់ជួបគ្នារួមភេទ។

តាមការបញ្ជាក់របស់នារីរងគ្រោះបានឲ្យដឹងថា ដំបូងឡើយរូបនាងពិតជាបានស្រឡាញ់ជនសង្ស័យជាសង្សារខ្លាំងណាស់ តែរយៈកាលក្រោយៗមក រូបនាងបែរជាមានការភ័យខ្លាចជាខ្លាំង ព្រោះតែជនសង្ស័យហាក់ដូច

ជាមនុស្សរោគចិត្ត ដ្បិតពេលរួមភេទជាមួយគ្នាម្តងៗ ជនសង្ស័យមិនត្រឹមតែថតវីដេអូទុកប៉ុណ្ណោះទេ រូបគេ(ជនសង្ស័យ) ថែមទាំងប្រើទារុណកម្មឃោរឃៅ ក្នុងពេលរួមភេទ ដូចជា ក្តិច ខ្ទាំ ខាំ ច្របាច់ មួលកដៃ និងវ៉ៃបែកមាត់លើរូបនាងជាញឹកញាប់ រហូតដល់នាងបែកចិត្តទៅភ្ជាប់ពាក្យជាមួយអ្នកថ្មី ។ ក្រោយពេលជនសង្ស័យ បានដឹងថានាងមានគូដណ្តឹង ជនសង្ស័យក៏បានប្រើហិង្សាលើរូប នាងចំនួន៦ដង និងគំរាមបង្ហោះវីដេអូរួមភេទជាមួយគ្នាផងដែរ។

នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៨ ខណៈដែលនារីរងគ្រោះ និងជនសង្ស័យនៅជាមួយគ្នា ស្រាប់តែគូដណ្តឹងនារីរងគ្រោះ បានឆាតមក ក៏ត្រូវជនសង្ស័យឆែកឃើញ បណ្តាលឲ្យមានការឈ្លោះប្រកែកគ្នា ហើយជនសង្ស័យបានឆាតទៅគំរាម គូដណ្តឹងនារីរងគ្រោះ ឲ្យឈប់ទាក់ទងនាងជាបន្ទាន់ បើមិនដូច្នោះទេ រូបគេនឹងធ្វើអ្វីមួយ ចំពោះគូដណ្តឹងនារីរងគ្រោះជាក់ជាមិនខាន ហើយបន្ទាប់មក ជនសង្ស័យបានបង្ខាំងនារីរងគ្រោះទុកក្នុងបន្ទប់ខុនដូ មិនឲ្យចេញទៅណា ព្រមទាំងបានចាប់បោចសក់ និងរុញផ្ទប់នារីរងគ្រោះទៅនឹងជញ្ជាំង ហើយបានខាំទៅលើជនរងគ្រោះ ២កន្លែង គឺដៃ១កន្លែង និងខាំកំប៉េះគូថ១កន្លែង បន្ទាប់មកជនសង្ស័យបានកាត់ក្រណាត់អាវយឺតជាកង់ៗ បំរុងយកមក ចងដៃ ចងជើងនាង តែដោយសារនារីរងគ្រោះអង្វរពេក ទើបរូបគេមិនបានចង ហើយក៏បង្ខំនារីរងគ្រោះឲ្យទូរស័ព្ទទៅនិយាយជាមួយគូដណ្តឹង ថាពួកគេទាំង២នាក់ រស់នៅជាមួយគ្នាជារៀងរាល់ថ្ងៃ បើនាងមិនទូរស័ព្ទទៅទេ ជនសង្ស័យគំរាមថា នឹងយកកន្ត្រៃមកកាត់សក់ចេញឲ្យអស់ ហើយសម្លាប់ចោលតែម្តង ទើបនារីរងគ្រោះបង្ខំចិត្តទូរស័ព្ទទៅគូដណ្តឹង និយាយតាមការគំរាមរបស់ជនសង្ស័យ ហើយ ជនសង្ស័យបានបង្ខាំងនាងទុកនៅក្នុងបន្ទប់ខុនដូ និងយកកាំបិតចុងស្រួច សស្ទាចមួយ គំរាមនាងមិនឲ្យចេញទៅណាជាដាច់ខាត។

លុះដល់ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៨ ម្តាយមីងរបស់នារីរងគ្រោះ បានបាត់ដំណឹងក្មួយស្រីពេញមួយយប់ ក៏បានដាក់ពាក្យបណ្តឹង មកកាន់បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញឲ្យជួយស្រាវជ្រាវ រហូតឈានទៅដល់រកឃើញទីតាំងបង្ខាំងទុកផ្ទាល់ ដោយមានការសហការជាមួយសមត្ថកិច្ចអាវុធហត្ថខណ្ឌចំការមន។ ពេលដែលសមត្ថកិច្ចអាវុធហត្ថចុះទៅដល់ ជនសង្ស័យមិនព្រមបើកទ្វារនោះទេ ថែមទាំងគំរាមសមត្ថកិច្ចថា រូបគេនឹងសម្លាប់នារីរងគ្រោះចោល ក្នុងបន្ទប់ទៀតផង បន្ទាប់មកជនសង្ស័យបានយក ស្ព្រាយបាញ់ទៅ លើទ្វារកញ្ចក់ មិនឲ្យសមត្ថកិច្ចមើលឃើញដល់ក្នុងបន្ទប់ បម្រុងរត់គេចខ្លួន តែមិនអាចចេញទៅណារួច ក៏ត្រូវបានកម្លាំងសមត្ថកិច្ចអាវុធហត្ថទម្លាយ ទ្វារចូលទៅឃាត់ខ្លួន និងរំដោះជនរងគ្រោះបានតែម្តង។ បន្ថែមពីករណីលើនេះទៅទៀត តាមការធ្វើតេស្តទឹកនោមរបស់ជនសង្ស័យ សមត្ថកិច្ចអាវុធហត្ថរាជធានីភ្នំពេញ បានរកឃើញថា ជនសង្ស័យដែលជា មនុស្សកំណាចឃោរឃៅម្នាក់នេះ មានជាប់សារធាតុញៀនផងដែរ ៕

## ថៃប្រគល់ពលរដ្ឋខ្មែរផុតទោសពីរនាក់តាមច្រកព្រំដែន

http://www.rasmeinews.com/ September 20, 2018, 6:48 AM

*ដោយអ្នកស្នាក់/ឧត្តរមានជ័យ:* អាជ្ញាធរថៃបានបញ្ជូនពលរដ្ឋខ្មែររួចផុតទោសចំនួន២នាក់តាមច្រកអន្តរជាតិជាំសាងាំព្រំដែនក្នុងស្រុកអន្លង់វែងខេត្តឧត្តរមានជ័យ។កាលពីរសៀលថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨។ សមត្ថកិច្ចបានឱ្យដឹងថា៖

១.ឈ្មោះង៉ែតខៃនភេទស្រីអាយុ៣៨ឆ្នាំរស់នៅភូមិអូរស្វាយឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

២.អ៊ីណារ៉ានភេទប្រុសអាយុ២៨ឆ្នាំរស់នៅភូមិកាប់ក្រឡាញ់ឃុំត្រពាំងជងស្រុកបាកានខេត្តពោធិ៍សាត់។អ្នកទាំងពីរជាប់គុកនៅខេត្តស៊ីសាកេត។ដែលត្រូវថៃបានចាប់ខ្លួនកាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧ ពីបទឆ្លងដែនខុសច្បាប់ចូលកាប់ឈើក្រញូងក្នុងទឹកដីថៃ ៕S/

## សមត្ថកិច្ចឃាត់ខ្លួនមនុស្ស៧នាក់ក្នុងហាងម៉ាស្សាកោសជប់មួយកន្លែង

http://www.rasmeinews.com/ September 20, 2018, 7:27 AM

*ដោយៈចាន់តូ/ភ្នំពេញៈ* កម្លាំងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារ អនីតិជនបានចុះបង្ក្រាបហាងម៉ាស្សាកោសជប់ធ្វើសរសៃមានលួចបង្កប់សេវាផ្លូវភេទមួយកន្លែង។ ជាមួយនោះបានឃាត់ខ្លួនមនុស្សចំនួន៧និងវត្ថុតាងមួយចំនួនត្រង់ចំណុចផ្ទះលេខ៣៦០EoE តាមបណ្តោយផ្លូវ២០១១ ភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខកាលពីយប់ថ្ងៃទី១៩ខែកញ្ញា ឆ្នាំ២០១៨។ កម្លាំងចុះបង្ក្រាបនិងឆែកឆេរទីតាំងលួចលាក់បង្កប់សេវាកម្មផ្លូវភេទខាងលើ ជាលទ្ធផលបានឃាត់ខ្លួនមនុស្សចំនួន៧នាក់។ ក្នុងនោះឃាត់ខ្លួនប្តីប្រពន្ធដែលជាថៅកែហាងម៉ាស្សនោះដែលបុរសជាប្តីឈ្មោះ ម៉ុនចំរើនអាយុ៤១ឆ្នាំស្នាក់នៅកន្លែងកើតហេតុ។

ចំណែកឯប្រពន្ធឈ្មោះហ៊ុនស្រីអនអាយុ២១ឆ្នាំស្នាក់នៅជាមួយគ្នា។នារីម៉ាស្សាចំនួនប្រាំនាក់ទៀតជាជនរងគ្រោះរួមទាំងដកហូតបានវត្ថុតាងរួមមានឧបករណ៍ប្រើប្រាស់គ្រឿងញៀនចំនួន៤ ស្រោមប្រើប្រាស់ហើយ និងមិនទាន់ប្រើមួយចំនួន និងសម្ភារមួយចំនួនទៀត។

បច្ចុប្បន្នថៅកែប្តីប្រពន្ធនិងស្ត្រីម៉ាស្សាទាំង៥នាក់រួមទាំងវត្ថុតាង ត្រូវបានកម្លាំងសមត្ថកិច្ចនាំខ្លួនយកទៅសាកសួរនៅឯនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនដើម្បីរង់ចាំធ្វើការចាត់ការទៅតាមនីតិវិធីច្បាប់៕S/

## ឃាត់មនុស្ស១២នាក់បម្រុងឆ្លងដែនចូលកាប់ឈើក្រញូងដីថៃ

http://www.rasmeinews.com/ September 19, 2018, 3:24 PM

*ដោយអ្នស្មោច់/ឧត្តរមានជ័យៈ* កម្លាំងនគរបាលក្រុងបានឃាត់មនុស្សចំនួន១២នាក់ជាកម្មករ និងរថយន្តចំនួន១គ្រឿងម៉ាកកូរូឡាសេរីឆ្នាំ១៩៩៤ ពណ៌សំបកឪឡឹក ពាក់ស្លាកលេខភ្នំពេញ2I:3551។ នៅចំណុចភូមិផ្អុងសង្កាត់កូនគ្រៀលក្រុងសំរោងបម្រុងឆ្លងដែនចូលទៅទឹកដីថៃកាត់ឈើក្រញ៉ូងតាមភូមិដងទង់សង្កាត់កូនគ្រៀលក្រុងសំរោង។កាលពីវេលាម៉ោង៨យប់ថ្ងៃទី១៨ខែកញ្ញាឆ្នាំ២០១៨។ សមត្ថកិច្ចបានឱ្យដឹងថា មនុស្សទាំង១២នាក់មានឈ្មោះ ១.ឃើន សុខុន ភេទប្រុស អាយុ ៣៦ឆ្នាំ ជាមេខ្យល់ ។ ២.ខៃ រីម ភេទប្រុស អាយុ ៣៨ឆ្នាំ ក្រុងសំរោង។ ៣.លឿ លីប ភេទប្រុស អាយុ ២២ឆ្នាំ មានទីលំនៅភូមិពោធិវង្ស សង្កាត់បន្សាយរាក់ ក្រុងសំរោង។ ៤.អៀប ពេញភេទប្រុស អាយុ ១៩ឆ្នាំ ។ ៥.ឈិត ប៉ោង ភេទប្រុស អាយុ ២៧ឆ្នាំ ។ ៦.សំ លឿយ ភេទប្រុស អាយុ ៣៧ឆ្នាំ ។ ៧.ឈន កុសល ភេទប្រុស អាយុ ២៨ឆ្នាំ។ ៨.រឿ រិន ភេទប្រុស អាយុ ២៤ឆ្នាំ ។ ៩.ធាន ជី ភេទប្រុស អាយុ ៣៩ឆ្នាំ ។ ១០.លាម សារ៉ាន់ ភេទប្រុស អាយុ ៦១ឆ្នាំ។ ១១.ប៊ិនហុនភេទប្រុសអាយុ៣៥ឆ្នាំ។ ១២.សៅស៊ីមភេទប្រុសអាយុ៣៥ឆ្នាំ។ ករណីនេះកម្លាំងសមត្ថកិច្ចកសាងសំនុំរឿងបញ្ជូនទៅស្នងការដ្ឋានចាត់ការតាមនីតិវិធីច្បាប់៕S/

## អាម៉ាស់ណាស់! អ្នកបម្រើសញ្ជាតិឥណ្ឌូណេស៊ីត្រូវបានផ្សាយ«លក់»នៅSingapore

http://www.cen.com.kh/archives/ September 20, 2018

ការផ្សាយពាណិជ្ជកម្មនេះបានរងទទួលនូវការរិះគន់ថាអយុត្តិធម៌ ខ្វះការគោរព ហើយកំពុងត្រូវបានរដ្ឋាភិបាលSingapore ស៊ើបអង្កេត។ តាមAFP បច្ចុប្បន្ន Singapore មានអ្នកបម្រើការ២៥០០០នាក់ក្នុងនោះភាគច្រើនមកពីតំបន់ក្រីក្រនៅឥណ្ឌូណេស៊ីហ្វីលីពីន។ពួកគេសង្ឃឹមថាបានមកកាន់ប្រទេសអ្នកមានមួយនេះដើម្បីទទួលបានប្រាក់ចំណូលខ្ពស់ផ្ញើទៅជួយដល់គ្រួសារខ្លួននៅឯស្រុកកំណើត។ ប៉ុន្តែព័ត៌មានស្តីពីការ«ពពាយនាយលក់»អ្នក

បម្រើការផ្លូវណេសុីនៅលើគេហទំព័រ Carousell របស់Singapore កាលពីថ្ងៃទី១៩កញ្ញាម្សិលមិញនេះបានទាក់ទាញចំណាប់អារម្មណ៍និងរងការថ្កោលទោសរបស់ក្រុមសិទ្ធិមនុស្ស។ ការផ្សាយពាណិជ្ជកម្មទាំងនោះអាស្រ័យដោយគណនីមួយមានឈ្មោះថា «ជ្រើសរើសអ្នកបម្រើ»ដែលបានបង្ហោះលើ បណ្តាញសង្គម ដោយអំពាវនាវឱ្យប្រើសេវាកម្មអ្នកបម្រើផ្លូវណេសុី ដោយមានអមជាប់ជាមួយនូវបញ្ជីអ្នកបម្រើត្រូវបាន«លក់»។

Wahyu Susilo នាយកប្រតិបត្តិនៃអង្គការក្រៅរដ្ឋាភិបាលការពារជនចំណាកស្រុកឱ្យដឹងថា ទង្វើនេះគប្បីត្រូវបានថ្កោលទោសយ៉ាងខ្លាំងក្លា ហើយអ្នកចុះផ្សាយព័ត៌មាននេះគួរត្រូវបានបញ្ជូនឱ្យតុលាការកាត់ទោស។ព្រោះថាវាជាទង្វើអយុត្តិធម៌ ខ្វះការគោរពចំពោះពលករចំណាកស្រុក។

ក្រសួងពលកម្ម Singapore បានកត់ត្រាទុកបញ្ហា«អំពាវនាវលក់មិនសមស្រប»អ្នកបម្រើការលើគេហទំព័រ Carousell ដែលមានស្នាក់ការនៅSingapore ។គេបានបញ្ជាឱ្យលុបចោលការផ្សាយពាណិជ្ជកម្មបែបនេះ ហើយ Singapore នឹងបើកការស៊ើបអង្កេត។ ក្នុងសេចក្តីប្រកាសរបស់ក្រសួងនេះបានលើកឡើងថា ការផ្សាយពាណិជ្ជកម្មអំពីអ្នកបម្រើការងារដោយប្រៀបប្រដូចទៅនឹងទំនិញគឺជាទង្វើមិនអាចទទួលយកបានហើយបំពានច្បាប់។ តាមនោះក្រុមហ៊ុនដែលធ្វើសេវាផ្គត់ផ្គង់ពលករបរទេស ដោយបំពាននឹងត្រូវដកហូតអាជ្ញាប័ណ្ណឬផ្អាកលិខិតអនុញ្ញាតអាជីវកម្ម៕ សូយន

# ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨

## ឃាត់ខ្លួនស្ត្រីម្ចាស់ហាងម៉ាស្សាកោសជប់ធ្វើសសៃសង្ស័យបង្កប់សេវាផ្លូវភេទ

http://nokorwatnews.com/ September 21, 2018,

ខេត្តពោធិ៍សាត់៖ ដោយមានការសម្របសម្រួលពីលោកព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តពោធិ៍សាត់ កម្លាំងជំនាញមន្ទីរយុត្តិធម៌ នៃបញ្ជាការដ្ឋាន កងរាជអាវុធហត្ថខេត្តពោធិ៍សាត់ បានចុះបង្ក្រាបទីតាំងសព្វកម្មមួយកន្លែង សង្ស័យមានបង្កប់សេវាផ្លូវភេទ ក្នុងនោះកម្លាំងឃាត់ខ្លួនស្ត្រីម្ចាស់ហាង និងនារីៗចំនួន ៤នាក់ រួមទាំងវត្ថុតាងផ្សេងៗផងដែរ ។

ប្រតិបត្តិការខាងលើធ្វើឡើងនៅវេលាម៉ោង៨និង១០នាទីយប់ ថ្ងៃអង្គារ ៩កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨ ត្រង់ចំណុចទីតាំងសព្វកម្មបម្រើផ្លូវភេទមួយកន្លែង ស្ថិតក្នុងភូមិរ៉ា សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។

ប្រភពព័ត៌មានពីកម្លាំងចុះប្រតិបត្តិការខាងលើបានឲ្យដឹងថា ក្នុងកិច្ចប្រតិបត្តិការនេះ កម្លាំងបានឃាត់ខ្លួនម្ចាស់ហាង ស្រីម៉ាន់ ម៉ាស្សា ម៉ាស្សាប្រេង កោសជប់ ឈ្មោះ គាវ ស្រីម៉ាន់ ភេទស្រី អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ បច្ចុប្បន្ន រស់នៅភូមិ សង្កាត់កើតហេតុ មានទីលំនៅភូមិដោប ឃុំតាអូរ ស្រុកគីរីវង់ ខេត្តតាកែវ។ ក្នុងកិច្ចប្រតិបត្តិការបានរកឃើញ និងដកហូតនូវវត្ថុតាងរួមមាន ស្រោមអនាម័យប្រើប្រាស់រួចចំនួន ០១ និងមិនទាន់ប្រើប្រាស់មួយចំនួន រួមទាំងកែវជប់មួយកញ្ជ្រែង និងជនរងគ្រោះចំនួន ០៤នាក់ផងដែរ។

ប្រភពព័ត៌មានខាងលើបន្តថា នារីៗជាជនរងគ្រោះទី១ ឈ្មោះ ផ សម អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ, ទី២ ឈ្មោះ គ ភ អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ, ទី៣ ឈ្មោះ ហ ធរ អាយុ ២០ឆ្នាំ និងទី៤ ឈ្មោះ ស ឡអ អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ ។ ប្រភពដដែលបន្តទៀតថា ចំពោះជនសង្ស័យជាម្ចាស់ហាងឈ្មោះ គាវ ស្រីម៉ាន់ និងនារីៗរងគ្រោះ បានបន្តនីតិវិធីនៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តពោធិ៍សាត់ ដើម្បីបំពេញសំណុំឯកសារពាក់ព័ន្ធផ្សេងៗ ដោយឡែក៖ ម្ចាស់ហាងយីហោ(ស្រីម៉ាន់ម៉ាស្សា) បានបញ្ជូនបន្តទៅសាលាដំបូងខេត្តពោធិ៍សាត់ចាត់ការបន្ត ៕ ប៉ឹម ពិន

## ក្រៅពីធ្វើស្រែចម្ការហើយគាត់នៅបន្តដាំដំណាំទៀត ប្រសើរជាងចំណាកស្រុក

https://kohsantepheapdaily.com.kh/article/ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៨ ម៉ោង ០៨:១០ ប៊ុន ជឿន

ខេត្តបន្ទាយមានជ័យ ៖ ប្រជាកសិករស់នៅតាមដងស្ទឹងមង្គលបូរីទំនេរពីធ្វើស្រែបាននាំគ្នាដាំស្ពៃលក់នៅទីផ្សាក្នុងស្រុកអាចជួយដល់ជីវភាពដោយមិនបាច់ចំណាកស្រុកធ្វើនៅប្រទេសក្រៅ ។ ប្រជាកសិករដែលដាំដំណាំស្ពៃបានប្រាប់ថា ប្រជាកសិករទំនេរពីធ្វើស្រែបាននាំគ្នាដាំបន្លែដំណាំបន្លែស្ពៃ តាមដងស្ទឹង ស្ថិតក្នុងភូមិនាងកេត ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ។ ប្រជាកសិករបានបញ្ជាក់ថា នៅអំឡុងពីនេះ គឺភាគច្រើនប្រជាកសិករដាំដំណាំស្ពៃខាត់ណា ដាំរយៈពេលជាង៣០ថ្ងៃ ទទួលផលលក់១គីឡូក្រាម តម្លៃ៣.០០០រៀល និងស្ពៃសរ ដាំរយៈពេល១៥ថ្ងៃទទួលផល១គីឡូក្រាមតម្លៃ២.០០០រៀល ស្ពៃថៃស៊ីម រយៈពេល២៥ថ្ងៃទទួលផល១គីឡូក្រាមតម្លៃ១.៥០០រៀល ដែលដាំជារបៀបគ្រួសារមានផ្ទៃដីដាំជាមធ្យម៥០ម៉ែត្រ គុណ៧០ម៉ែត្រ ដែលអាចរកចំណូលដាំក្នុងវគ្គបានប្រមាណ១ទៅ២លានរៀល ។

ប្រជាកសិករបានប្រាប់ថា ការដាំដំណាំស្ពៃដែលប្រជាកសិករដាំងាយស្រួលដាំ និងទីផ្សាលក់ឲ្យឈ្មួញមកទទួលទិញមកដល់ចម្ការលក់ទីផ្សាក្នុងស្រុក ដែលបានកម្រៃប្រសើរជាងធ្វើចំណាក់ស្រុកទៅប្រទេសក្រៅ តែសុំមន្ត្រីជំនាញជួយផ្តល់បទពិសោធន៍ការដាំបន្លែ ហើយកន្លងមកដាំតាមគ្នា តែទទួលផលមិនបានល្អប៉ុន្មានទេ ។

លោកផាន់ ណារ៉ា អនុប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខេត្តបន្ទាយមានជ័យបានប្រាប់ថា ខេត្តបន្ទាយមានជ័យឆ្នាំ២០១៨នេះ ប្រជាកសិករដាំបន្លែគ្រប់មុខ មានផ្ទៃដី២.១៤៣ហិកតា បើប្រៀបធៀបឆ្នាំ២០១៧ មានផ្ទៃដីដាំបន្លែមាន១.៣៧៨ហិកតាដោយនៅស្រុកមង្គលបូរី មានផ្ទៃដីដាំបន្លែមាន៣២៩ហិកតា ។ លោកបានបញ្ជាក់ថា ការដាំបន្លែភាគច្រើនប្រជាកសិករដាំនៅពេលដែលទំនេរ ពីធ្វើស្រែនាំគ្នាធ្វើចម្ការដែលមន្ត្រីជំនាញបានធ្វើការណែនាំឲ្យដាំតាមលក្ខណៈបច្ចេកទេស ទើបទទួលផលល្អ និងងាយរកទីផ្សារ ៕

## ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨

## ពលរដ្ឋខ្មែរ២នាក់ស្លាប់ ៤នាក់របួសធ្ងន់ ករណីក្រឡាប់រថយន្តពេលធ្វើដំណើរទៅរកការងារធ្វើក្នុងប្រទេសថៃ

http://cambodiapolice.com/policekh/ 10:17 am 23 កញ្ញា 2018

ខេត្តបន្ទាយមានជ័យ ៖ ពលករខ្មែរចំនួន៦នាក់បានជិះរថយន្តឈ្នួលរបស់ថៃ នៅតាមផ្លូវស្រោប់តែផ្ទុះកង់រថយន្ត បណ្តាលឲ្យស្លាប់២នាក់ និងរបួសធ្ងន់៤នាក់ នៅវេលាម៉ោង៥ល្ងាច ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ នៅចំណុចស្រុកកាប៊ីនបូរី ខេត្តប្រាជីនបូរី ប្រទេសថៃ ។

តម្រួតថៃបានប្រាប់សមត្ថកិច្ចខ្មែរឲ្យដឹងថា ពលករខ្មែរជួបគ្រោះថ្នាក់ចរាចរណ៍ស្លាប់ រួមមាន ៖ ១-ឈ្មោះ ម៉ៅ ម៉ូលីកា ភេទស្រី អាយុ៣០ឆ្នាំ មានទីលំនៅភូមិខ្នា សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាម ។ ទី២-ឈ្មោះ ដុក លីដា ភេទស្រី អាយុ២០ឆ្នាំ មានទីលំនៅភូមិឫស្សីក្រោក ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ។ ចំណែកអ្នករបួសមានឈ្មោះ១-ឈ្មោះ កេត គន្ធា ភេទស្រី អាយុ២០ឆ្នាំ មានទីលំនៅភូមិ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ របួសបាក់ចង្កេះ ។ ទី២-ឈ្មោះ សុង ពិសី ភេទស្រី អាយុ១៨ឆ្នាំ មានទីលំនៅភូមិវត្តស្វាយ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប របួសភ្នែកឆ្វេង ។ ទី៣-ឈ្មោះ ជា ស៊ុយលី ភេទស្រី អាយុ២៤ឆ្នាំ មានទីលំនៅភូមិកិត្តិយស ឃុំព្រៃជ្រូក ស្រុកពួក ខេត្តសៀមរាប របួសជើង និងទី៤-ឈ្មោះ រឹទ្ធ សុលាភ ភេទប្រុស អាយុ២១ឆ្នាំ មានទីលំនៅភូមិមណ្ឌល ឃុំស្វាយដង្គំ ក្រុង-ខេត្តសៀមរាប របួសក្បាល ។

សមត្ថកិច្ចថៃបានបញ្ជាក់ឲ្យដឹងទៀតថា នៅមុនពេលកើតហេតុនោះ ពលករខ្មែរចំនួន៦នាក់ធ្វើដំណើរតាមរថយន្តឈ្នួល ដើម្បីទៅទិញអីវ៉ាន់ នៅទីក្រុងបាងកក ។ លុះបើកមកដល់ចំណុចកើតហេតុ ស្រាប់តែរថយន្តផ្ទុះកង់បណ្តាលឲ្យក្រឡាប់ធ្លាក់ចូលប្រឡាយ ក្រោយពីមកពេលតម្រួតទៅដល់យកមនុស្សចេញពីរថយន្ត ពលករបានស្លាប់២នាក់ និង៤នាក់ទៀតរងរបួសធ្ងន់ ។

ក្រោយពីកើតហេតុ ជនរងគ្រោះត្រូវបានបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យក្នុងប្រទេសថៃ ចំណែកអ្នកស្លាប់ត្រូវបានអគ្គកុងស៊ុលកម្ពុជាប្រចាំប្រទេសថៃ រៀបចំបែបបទបញ្ជូន មកប្រទេសកម្ពុជាវិញ តាមច្រកអន្តរជាតិប៉ោយប៉ែតជាបន្តបន្ទាប់ដើម្បីប្រគល់សពទៅឲ្យក្រុមគ្រួសារយកទៅធ្វើបុណ្យនៅស្រុកកំណើតតាមប្រពៃណី ៕

## ថៃចាប់ខ្មែរ ៦ នាក់ និងយោធាម្នាក់ តែដោះលែងវិញក្រោយចរចា

https://www.postkhmer.com/ ឃុត សុភចរិយា | Publication date 24 September 2018 | 08:25 ICT

**ភ្នំដងរែក:** មន្ត្រីយោធាការពារព្រំដែនកម្ពុជា-ថៃប្រចាំតំបន់ជួរភ្នំដងរែក បានប្រាប់ឲ្យដឹងនៅថ្ងៃម្សិលមិញថា ក្រុមទាហានឈុតប៉ារ៉ាថៃបានល្បាតបំពានចូលក្នុងទឹកដីកម្ពុជា ហើយបានចាប់ឃាត់ខ្លួនពលរដ្ឋខ្មែរ ៦ នាក់ និងយោធាម្នាក់ដោយចោទប្រកាន់ថា បានព្យាយាមឆ្លងដែនចូលទៅកាប់ឈើគ្រញូងក្នុងទឹកដីរបស់ពួកគេដោយខុសច្បាប់ថៃទៀត។

លោក រស់ សារួម មេបញ្ជាការកងអនុសេនាធំលេខ ១ ប្រចាំតំបន់ជួរភ្នំដងរែក បានប្រាប់ភ្នំពេញប៉ុស្តិ៍ថា កាលពីថ្ងៃទី ២១ និង ២២ ខែកញ្ញា ឆ្នាំ ២០១៨ ក្រុមទាហានឈុតប៉ារ៉ាថៃប្រមាណ ១០ នាក់បានចូលលុកលុយតំបន់ព្រំដែនក្នុងទឹកដីកម្ពុជាក្នុងចន្លោះប្រមាណពី ២០០ ម៉ែត្រទៅ ៣០០ ម៉ែត្រ និងបានចាប់ឃាត់ខ្លួនពលរដ្ឋខ្មែរមួយចំនួនក្នុងនោះមានម្នាក់ជាមន្ត្រីយោធាដែលបម្រើការងារនៅបញ្ជាការដ្ឋានកងអនុសេនាធំលេខ ២ ដោយចោទប្រកាន់ថាបានប៉ុនប៉ងឆ្លងចូលទៅកាប់ឈើនៅក្នុងទឹកដីថៃដោយខុសច្បាប់។ ប៉ុន្តែពួកគេបានដោះលែងវិញភ្លាមៗផងដែរ បន្ទាប់ពីមានកិច្ចអន្តរាគមន៍ពីក្រុមមន្ត្រីយោធាទំនាក់ទំនងកិច្ចការព្រំដែននៃប្រទេសទាំង ២ មកសម្រុះសម្រួល និងចុះពិនិត្យយាមកាមនៅលើផែនទីភូមិសាស្ត្រ ហើយបានបង្ហាញថាតំបន់ដែលភាគីថៃបានលុកលុយនោះគឺស្ថិតនៅក្នុងទឹកដីកម្ពុជា។ លោក សារួម ថាមន្ត្រីយោធាដែលត្រូវភាគីថៃចាប់ឈ្មោះ ផល ឡាត់ អាយុ ៣៨ ឆ្នាំ បម្រើការនៅអង្គភាពកងអនុសេនាធំទី ២ មានឋានៈជានាយចំណង់។ នៅពេលនេះកម្លាំងយោធាការពារព្រំដែនកម្ពុជាកំពុងបង្កើនការចុះល្បាតតាមព្រំដែនដើម្បីការពារបទល្មើសតាមព្រំដែនផង និងការពារការទន្ទ្រានលុកលុយពីកម្លាំងយោធាឈុតប៉ារ៉ាថៃចូលមកក្នុងទឹកដីកម្ពុជាក្រោមលេសចុះល្បាតតាមព្រំដែនផង។

លោក តូច រ៉ា ប្រធានស្នាក់ការទំនាក់ទំនងព្រំដែនកម្ពុជាថៃប្រចាំនៅច្រកទ្វារអន្តរជាតិជាំបានឲ្យដឹងតាមទូរស័ព្ទថា យោងតាមការអះអាងពីខាងភាគីថៃ មន្ត្រីយោធាកម្ពុជាដែលត្រូវភាគីថៃចាប់ខ្លួននោះ គឺដោយសារតែពេលនោះពួកគេបានប្រទះឃើញគាត់ជិះម៉ូតូកាត់តាមដងព្រៃតាមជួរបន្ទាត់ព្រំដែន ដោយសង្ស័យទើបឃាត់ខ្លួនដើម្បីសួរនាំព្រោះកន្លងមកមានបទល្មើសឆ្លងដែនចូលទៅកាប់ឈើនៅក្នុងទឹកដីថៃ។ លោក រ៉ា ថា៖ «ប៉ុន្តែករណីនេះត្រូវបានដោះស្រាយដោយភាគីថៃបានសុំទោសចំពោះការឃាត់ខ្លួនមន្ត្រីយោធាយើង ព្រោះយើងជិះតែក្នុងទឹកដីយើង តែពួកគេទេដែលបានចុះល្បាតរំលោភចូលក្នុងទឹកដីយើង»៕

## ពលករខ្មែរជាង១ម៉ឺននាក់ជាអ្នកនេសាទសមុទ្រនៅប្រទេសថៃ

http://www.rasmeinews.com/ September 24, 2018, 5:00 PM

*អត្ថបទ:សុផានីតា/កោះកុង:* តាមរយៈប្រធានរដ្ឋបាលជលផលខេត្តត្រាត ប្រទេសថៃមន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃថ្លែងថា បច្ចុប្បន្នខេត្តត្រាតមានពលករខ្មែរជាង១ម៉ឺននាក់កំពុងធ្វើការលើទូកនេសាទសមុទ្ររបស់ថៅកែថៃ។ ភាគច្រើនពលករកម្ពុជាមានឯកសារបញ្ជាក់ស្របច្បាប់ក្រោយពីមន្ត្រីក្រសួងការងារ និងអគ្គនាយកដ្ឋានអត្តសញ្ញាកម្មចុះសម្រប សម្រួលដោះស្រាយជូនពួកគាត់។ ពលករនេសាទកម្ពុជាប្រមាណជាង១ម៉ឺននាក់ដែលកំពុងបម្រើការងារជាអ្នកនេសាទសមុទ្រនៅខេត្តត្រាត ប្រទេសថៃ ជាប់នឹងខេត្តកោះកុងព្រំដែនអន្តរជាតិប្រទេសកម្ពុជា។ បើតាមមន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃពលករខ្មែរភាគច្រើនមានឯកសារបញ្ជាក់ស្របច្បាប់ គឺនៅតែចំនួនតូចប៉ុណ្ណោះដែលអាជ្ញាធរ ស្វែងរកផ្តល់ភាពស្របច្បាប់ជូនពួកគាត់។

ក្នុងដំណើរបេសកម្មការងាររយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី២២ដល់ថ្ងៃទី២៣ ខែកញ្ញាថ្មីៗនេះទៅកាន់ខេត្តត្រាត ប្រទេសថៃ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សកម្ពុជា។ អមដំណើរដោយលោកស្រីអភិបាលខេត្តកោះកុងផងនោះបានថ្លែងថា ការងារនេសាទរបស់ពលករខ្មែរនៅប្រទេសថៃការងារមួយដ៏ស្មុគស្មាញនិងលំបាកគ្រប់គ្រងដែលរដ្ឋាភិបាលផ្តោតយកចិត្តទុកដាក់សម្របសម្រួលដោះស្រាយ។ ដូច្នេះទើបកម្ពុជាចង់ទទួលព័ត៌មានផ្លូវការមួយលើដំណើរការរៀបចំប្រព័ន្ធការពារសុវត្ថិភាពរបស់ភាគីថៃសម្រាប់ផ្តល់ប្រយោជន៍ជូនពលករខ្មែរនិងថៅកែក្រុមហ៊ុន។ លោកស្រីរដ្ឋលេខាធិការក្រសួងមហាផ្ទៃ បន្ថែមទៀតថា កន្លងទៅ លោកស្រីមានព័ត៌មានថា ពលករខ្មែររហូតដល់ទៅជាង ១.៧០០នាក់ នៅសមាគមនេសាទសមុទ្រខេត្តត្រាតពុំទាន់មានឯកសារបញ្ជាក់ផ្លូវច្បាប់ត្រឹមត្រូវ និងអាចរង់ការរំលោភបំពានសិទ្ធិជាដើម។ប៉ុន្តែជាង១មុននឹងលោកស្រីចុះមកពិនិត្យត្រូវបានមន្ត្រីកម្ពុជា និងភាគីថៃផ្តល់ដំណឹងថាបានរៀបចំបែបបទធ្វើលិខិតឯកសារស្របច្បាប់ជិតបញ្ចប់អស់ហើយ។ ទោះយ៉ាងណាលោកស្រីនៅតែចង់សិក្សាស្វែងបន្ថែមទៀតអំពីនីតិវិធីទាំងនោះហេតុអីឆាប់រហ័សដូច្នេះ។ ជាក់ស្តែងការបំពេញឯកសារខាងលើជា Border Passព្រំដែនប៉ុណ្ណោះ។ហើយការប្រើប្រាស់បណ្ណព្រំដែននៅមិនទាន់គ្រប់លក្ខណៈចំពោះយន្តដោះស្រាយភាពស្របច្បាប់ជូនពលករខ្មែរនៅឡើយទេ។ លោកស្រី ជូ ប៊ុនអេង ក៏បានស្នើទៅអាជ្ញាធរភាគីថៃដែរ បើពលករខ្មែររស់នៅក្នុងប្រទេសថៃ មានបញ្ហាអ្វីមួយសូមឱ្យភាគីថៃជួយសម្របសម្រួលដល់ពលករខ្មែរផងឬផ្តល់ជាព័ត៌មានពិតប្រាកដមកអាជ្ញាធរកម្ពុជាភ្លាមៗ ដើម្បីរួមគ្នាដោះស្រាយបញ្ចប់។

លោក សាន់សេន សេរីវ៉ាត់ ប្រធានរដ្ឋបាលជលផលខេត្តត្រាត ប្រទេសថៃ បានឱ្យដឹងថា អាជ្ញាធរថៃកំពុងរៀបចំនីតិវិធីចុះបញ្ជីទូកនិងកម្មករនេសាទដោយច្បាស់លាស់ដោយអាចភាគីអាជ្ញាធរកម្ពុជាទទួលយកបាននាពេលបច្ចុប្បន្ននេះផងដែរខណៈពលករខ្មែរដែលបម្រើការងារនេសាទសមុទ្រចាប់ពី២ទៅ៣ឆ្នាំឡើងខ្លះមាននិងខ្លះទៀតនោះពុំទាន់មានឯកសារស្របច្បាប់នៅឡើយ។ លោក សេរីវ៉ាត់ ក៏ពេញចិត្តនឹងដំណើរបេកសកម្មរបស់មន្ត្រីជាន់ខ្ពស់កម្ពុជា លើសិក្សាស្វែងយល់ និងដោះស្រាយផ្តល់ឯកសារស្របច្បាប់ជូនពលករខ្មែរជៀសវាងមានបញ្ហាលំបាកជួយសង្គ្រោះនៅពេលមានបញ្ហាណាមួយកើតមានឡើង។

ដោយឡែកលោក សេង ផាត ពលរដ្ឋមកពីខេត្តបាត់ដំបងនិងយុវជនតាន់ឡាមកពីខេត្តកំពតសព្វថ្ងៃជាពលករខ្មែរដែលបម្រើការចុះទូកនេសាទនៅខេត្តត្រាតបានលើកឡើងថា ពួកគាត់មានប័ណ្ណការងារលិខិតឆ្លងដែនដែលទទួលស្គាល់ពីក្រសួងការងារ និងរដ្ឋាភិបាលកម្ពុជា ទើបអាចធ្វើការជាអ្នកនេសាទនៅប្រទេសថៃបាន។ ករណីផុតកំណត់ប្រើប្រាស់ ពួកគាត់នឹងបំពេញបែបបទបន្តទៀត។ ក្រុមពលករ ឱ្យដឹងដែរថា រីឯថៅកែក្រុមហ៊ុនបើកប្រាក់ខែ

ជូនពួកគាត់ទៀងទាត់ជូន១ម៉ឺនបាត ក្នុង១ខែ ឬលើសនេះក៏មានគ្មានបង្ខំឱ្យធ្វើការលើសម៉ោងទេគឺមានពេលវេលាសម្រាកត្រឹមត្រូវ។ប្រាក់ខែដែលបានមកផ្ញើមកម្តាយឪពុកនិងប្រពន្ធនៅស្រុកកំណើត ក៏ដូចជាទុកនៅខ្លួនឯងខ្លះ។

បើតាមលោកស្រី រដ្ឋលេខាធិការក្រសួងមហាផ្ទៃដើម្បីកាន់តែទទួលព័ត៌មានច្រើនពីភាពល្អប្រសើរ និងចង់ដឹងបញ្ហាប្រឈមនានារបស់ពលករខ្មែរពិសេសបញ្ហាការជួញដូរមនុស្សលោកស្រីដឹកនាំក្រុមការងារជំនាញនឹងបន្តទៅបេសកម្មទៅកាន់ខេត្តដ៏ទៃទៀតក្នុងប្រទេសថៃនាពេលខាងមុខ៕S/

## តើលោកឧត្តមសេនីយ៍ទោ តុន ញៀន ទុកឱ្យពលករឆ្លងដែនកាប់ឈើក្រញូងស្លាប់ ក្រោមគ្រប់កាំភ្លើងថៃដល់ពេលណាទៀត

http://chnchannel.com/chnnewws/ ថ្ងៃទី 24 ខែ កញ្ញា ឆ្នាំ 2018 254

**ឧត្តរមានជ័យ៖** តើលោកឧត្តមសេនីយ៍ទោ តុន ញៀន មេបញ្ជាការសឹករងខេត្តឧត្តរមានជ័យ ឆ្ងាញ់ណាស់ទៅរឺចំពោះលាភសក្ការដែលបានមកពី បទល្មើសចរាចរណ៍ឈើក្រញូងឆ្លងដែននៅតំបន់ទិសទី២ សមរភូមិមុខស្រុកអន្លង់វែង និងស្រុកត្រពាំងប្រាសាទ ទើបទុកឱ្យប្រជាពលរដ្ឋ និងជាពលករឆ្លងដែនកាប់ឈើក្រញូង ស្លាប់រងរបួសជាប់គុករៀងរាល់ខែដល់ពេលណាទើប ទើបលោកឆ្អែត និងមានវិធានការទប់ស្កាត់ម្តង។ ដែលនៅក្នុងតំបន់ទិសទី២ សមរភូមិមុខ ស្រុកអន្លង់វែង និងស្រុកត្រពាំងប្រាសាទខេត្តឧត្តរមានជ័យ ល្បីស្ទើរាងរាល់ថ្ងៃ ក្នុងការបាញ់សម្លាប់ចាប់ដាក់គុក និងរងរបួស កើតមានស្ទើរគ្រប់ទិសទី ក្រោយពីមានការបែកធ្លាយពលករក្នុងចំណោម៦ ម្នាក់បានដោះលែង និងម្នាក់ស្លាប់ និង៤នាក់ទៀតត្រូវបានជាប់គុក នៅថ្ងៃទី២១និងថ្ងៃទី២២ ខែកញ្ញានេះ ក្នុងភូមិសាស្រ្តបានតាវែង ខេត្តសុរិនប្រទេសថៃ ព្រំប្រទល់ភូមិសាមគី ឃុំត្រពាំងប្រិយ ស្រុកអន្លង់វែង។ មិនតែប៉ុនណ្ណោះមានករណីបាញ់សម្លាប់ ពីសំណាក់យោធាថៃ មកលើពលករខ្មែរ ជារាងរាល់ខែមិនដែលស្រាកស្រាន្តម្តងណាឡើយ។ ហើយសកម្មភាពមេខ្លោងនាំពលករឆ្លងដែន និងមេឈ្មួញនៅតែឃើញបន្តរកើតមានជាហូរហែទាំងយប់ទាំងថ្ងៃយ៉ាងអនាធិបតេយ្យនៅតាមបន្ទាត់ព្រំដែនស្រុកអន្លង់វែងនិងស្រុកត្រពាំងប្រាសាទ មានទាំងសមត្ថកិច្ចចូលរួមទៀតផង ។

គួសរំលឹកផងដែលថា នៅថ្ងៃទី២១និងថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៨នេះ មានសេចក្តីរាយការណ៍មកថាក្នុងចំណោមពលករឆ្លងដែនកាប់ឈើក្រញូង៦នាក់ ត្រូវបានយោធាថៃបាញ់សម្លាប់ម្នាក់ ដោះលែងម្នាក់ជាយោធា និងឃាត់ខ្លួនផ្តន្ទាទោស៤នាក់ នៅចំណុចបានតាវែង ខេត្តសុរិនថៃ ព្រំប្រទល់ភូមិសាមគ្គីឃុំត្រពាំងប្រិយស្រុកអន្លង់វែង។ ប្រភពបានបង្ហើបថា និងបានស្លាប់ជាបន្តរបន្ទាប់ជារាងរាល់ខែកាលពីកន្លងទៅ បើយោងទៅតាមរូបភាពនិងឯកសារ នៅថ្ងៃទី៨ ខែកញ្ញា យោធាថៃបាញ់ស្លាប់ម្នាក់ នៅចំណុចក្បាលអូខ្សាច់ និងមានជាបន្តបន្ទាប់ ដូចជានៅភូមិព្រះចំបក់ធ្វើបុណ្យដោយគ្មានសាកសព កាលពីថ្ងៃទី២៥ ខែសីហា ខ្លះ ទៀតករលួចយកសពមកបានធ្វើបុណ្យទៅ តាមប្រពៃណី នេះគ្រាន់តែរយៈពេលពីខែកន្លងផុតទៅ។

តែទោះជាយ៉ាងណាពលករកាប់ឈើក្រញូងស្លាប់និងរងរបួស និងជាប់គុករាងរាល់ខែ មិនស្រាកស្រាន្តយ៉ាងណាក្តីរកឃើញមេឈ្មួញដឹកជញ្ជូនចរាចរឈើក្រញូងយ៉ាងរលូននៅតាមបន្ទាត់ព្រំដែនទិសទី២សមរភូមិមុខខេត្តឧត្តរមានជ័យយ៉ាងរំភើយដ៏ដែល ទោះជាកងកម្លាំងយោធាសំពាយកាំភ្លើងសង្ហាតាមដងផ្លូវយ៉ាងណាក៏ដោយតែឈ្មួញអត់ខ្វល់ រឿងនេះគឺមិនបាច់សង្ស័យទេ គឺច្បាស់តែម្តង ឃុបឃិត។

ជាតុពិតការលះបង់សាច់ស្រស់ឈាមស្រស់ប្អូនរួមទាំង ជីវិតរបស់ពួកគាត់ គឺគ្រាន់តែ ជាឈ្នាន់ រកផលប្រយោជន៍ សម្រាប់រកលុយឱ្យក្រុមអ្នកមានអំណាចមួយក្តាប់តូចតែប៉ុណ្ណោះ នេះជាអំពើអយុត្តិធម៌សម្រាប់ពលករខ្មែរ ។ ជុំវិញករណីខាងលើក្រុមការងារយើងមិនអាចស្វែងរកសុំការបំភ្លឺពីឧត្តមសេនីយ៍ ទោ តន់ ញាណ បានទេព្រោះទូសព្ទចូលអត់ទទួល ទូសព្ទម្តងទៀតចុចដាប់រវល់៕ ដោយ: BRT

# ក្រុងស្វាយរៀងមានផ្ទះបនស្រីយ៉ាងអនាធិបតេយ្យហូតជិត ២០កន្លែង

http://fanidols.com/archives/ By fanidol September 22, 2018

ដូចជាយើងទាំងអស់គ្នាបានដឹងមកហើយថា សង្គមបច្ចុប្បន្នមិនថាតែនៅក្នុងប្រទេសកម្ពុជា ឬនៅក្នុងប្រទេសផ្សេងៗនោះទេសុទ្ធតែមានស្ត្រីរកស៊ីផ្លូវភេទទាំងអស់។ យើងធ្លាប់តែឃើញមានច្រើននៅក្នុងប្រទេសថៃ ដែលសំបូរជាងគេ ប៉ុន្តែពេលនេះនៅក្នុងប្រទេសកម្ពុជាយើងក៏មិនខុសពីគេដែរ គឺចំនួននៃស្ត្រីរកស៊ីផ្លូវភេទគឺបានកើនឡើងគួរឱ្យកត់សម្គាល់។ ជាក់ស្តែងប៉ុន្មានម៉ោងមុននេះមានបណ្តាញសារព័ត៌មានមួយឈ្មោះ ICDTV បានចុះឡាយវីដេអូផ្ទាល់នៅក្រុងស្វាយរៀងពាក់ព័ន្ធនឹងស្ត្រីរកស៊ីផ្លូវភេទយ៉ាងអនាធិបតេយ្យ ស្ថិតនៅត្រង់ចំនុចភូមិរពាងបន្លែ សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង។ តាមប្រភពព័ត៌មានដដែលនោះបានឱ្យដឹងថា ចំនួនទីតាំងដែលស្ត្រីរកស៊ីផ្លូវភេទមានរហូតដល់ទៅ ១៣កន្លែង ហើយបច្ចុប្បន្ន ពុំមានឃើញអជ្ញាធរ ក៏ដូចជាសមត្ថកិច្ចនៅទីនោះ ធ្វើការចាត់វិធានការចុះទៅបង្ក្រាបនោះទេ ។

# មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ ស្នើឱ្យភាគីថៃ ជួយសម្រួលដល់ពលករខ្មែរ ដែលរស់នៅប្រទេសថៃ, បើមានបញ្ហា សូមផ្តល់មកភាគីកម្ពុជា ដើម្បីធ្វើការដោះស្រាយគ្នា

http://freshnewsasia.com/index.php/ 2018-09-24

**(កោះកុង)៖** លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋានប្រយុទ្ធប្រឆាំង ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស រួមជាមួយលោកស្រី មិថុនា ភូថង អភិបាលខេត្តកោះកុង ព្រមទាំងទាំងមន្ត្រីក្រោមឱវាទ បានជួបពិភាក្សាជាមួយភាគីថៃ ព្រមទាំងបានចុះសួរសុខទុក្ខពលករនេសាទកម្ពុជា ដែលរស់នៅខេត្តត្រាត ប្រទេសថៃ។ ថ្លែងក្នុងឱកាសជួបពិភាក្សាជាមួយភាគីថៃ នៅចុងសប្តាហ៍ លោកស្រី ជូ ប៊ុនអេង បានថ្លែងថា ក្រុមការងារបានចុះមកដល់ខេត្តត្រាត ប្រទេសថៃ ក្រោមការណែនាំពីសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាក្រសួងមហាផ្ទៃ ដើម្បីជួបសំណេះសំណាលជាមួយពលករទូកនេសាទ ដែលមករកការងារ និងរស់នៅខេត្តត្រាត ដូចជា ចុះទូកធ្វើនេសាទជាដើម។ លោកស្រី ជូ ប៊ុនអេង បានថ្លែងបន្តទៀតថា ពលករនេសាទកម្ពុជាដែលប្រកបរបរចុះនេសាទនៅខេត្តត្រាតមានចំនួន១ម៉ឺននាក់ ហើយពលករទាំងអស់នោះមករស់នៅធ្វើនេសាទ គឺមានឯកសារស្របច្បាប់ត្រឹមត្រូវទាំងអស់ មានតែមួយចំនួនតូច ដែលគ្មានឯកសារស្របច្បាប់។ ចំពោះពលករនេសាទមួយចំនួនតូច ក្រុមការងារនឹងជម្រុញឱ្យពួកគាត់ធ្វើឯកសារ ដើម្បីរស់នៅប្រទេសថៃ មានភាពងាយស្រួល។ លោកស្រី បានស្នើសុំទៅភាគីថៃថា បើពលកររស់នៅក្នុងប្រទេសថៃ មានបញ្ហាអ្វីមួយ សូមឱ្យភាគីថៃជួយសម្របសម្រួលដល់ពលករខ្មែរផង និងសូមឱ្យភាគីថៃ ផ្តល់មកភាគីកម្ពុជាជាបន្ទាន់ ដើម្បីភាគីទាំងទ្វេរធ្វើការដោះស្រាយគ្នា។ ចំពោះការពិភាក្សាគ្នារវាងភាគីកម្ពុជា និងភាគីថៃឃើញថា រាល់បញ្ហាត្រូវបានដោះស្រាយគ្នាបាន ដោយរលូនមិនមានអ្វីរាំងស្ទះគឺទទួលបានលទ្ធផលល្អ។

លោក សេង ផាត់ ដែលជាពលករខ្មែរម្នាក់ខាងនេសាទ បានឱ្យដឹងថា គាត់បានមកធ្វើកម្មករទូករយៈពេលជិត៣ឆ្នាំហើយ ក្នុងខេត្តត្រាត ហើយមានអ្នកខ្លះរស់នៅ៤ទៅ៥ឆ្នាំ។ ការមករស់នៅប្រទេសថៃនេះ គាត់មានឯកសារស្របច្បាប់គ្រប់គ្នា មិនមានអ្វីព្រួយបារម្ភណ៍អ្វីនោះទេ ហើយការស្នាក់នៅមានការយកចិត្តទុកដាក់ មិនមានបញ្ហាអ្វីទេ ព្រោះប្រទេសថៃ មានច្បាប់ដូចប្រទេសយើងដែរ ចំពោះតម្លៃពលកម្មក្នុង១ខែ បានចំនួន១ម៉ឺនបាត។ បើយើងអូរត្រីបានច្រើន មានប្រាក់បន្ថែមពីលើទៀត ហើយការឈឺស្កាត់ថៅកែជាអ្នកចេញថ្លៃព្យាបាល។ លោកបានបន្ថែមថា ចំពោះប្រាក់ខែថៅកែបើកឱ្យរាល់ខែ មិនបាត់ទេ បើយើងចង់ដាក់កុងធនាគារគឺតាមចិត្តយើង។

បងស្រីម្នាក់ទៀត បាននិយាយថា គាត់មករស់នៅខេត្តត្រាតនេះ គឺមកហាលត្រីឱ្យគេ។ គាត់មកទាំងគ្រួសារ ហើយក្នុង១ខែម្នាក់ៗ ទទួលបានប្រាក់ខែ៩៣៣៣ត បាត ហើយប្រាក់ខែបានរាល់ខែមិនបាត់១រៀលឡើយ បាយទឹកនៅលើថៅកែឈឺស្កាត់ចូលអស់៣០បាត ស្មើ៣០០០រៀលប៉ុណ្ណោះ ហើយចំពោះថៅកែគាត់យកចិត្តទុកដាក់លើពួកគាត់ណាស់ ហើយយើងចង់ទៅលេងស្រុកកំណើត គាត់អត់ហាមឃាត់យើងឡើយ រាល់ថ្ងៃពួកគាត់ពិបាកតែម្យ៉ាង គឺបញ្ហាកូនអត់បានរៀនអក្សរខ្មែរតែប៉ុណ្ណោះ៕

## មុខរអាក្រក់ហើយ ចិត្តក៏កាន់តែរអាក្រក់...ចេះធ្វើជាក់សាច់ឈាមឯងទៅរួច

https://kohsantepheapdaily.com.kh/article/ ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៨ ម៉ោង ១៦:៥៣ ប៊ុន លីនណា

រាជធានីភ្នំពេញ ៖ ជនប្រុសស្រី២នាក់បងប្អូន ដែលនគរបាលកំណត់ថាជាមុខសញ្ញារកស៊ីជួញដូរមនុស្សទៅក្រៅប្រទេស បានត្រូវចាប់ខ្លួននិងបញ្ជូនបន្តទៅឃុំខ្លួននៅពន្ធនាគារ បន្ទាប់ពីបើកការស៊ើបអង្កេតបឋមមួយដោយនគរបាលប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនហើយរកឃើញថា ពួកគេទាំង២នាក់ធ្លាប់បានធ្វើសកម្មភាពលក់ក្មួយស្រីបង្កើត ឲ្យទៅបុរសជនជាតិចិននៅប្រទេសចិនកាលពី២ឆ្នាំមុន ។

នគរបាលប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនបានឲ្យដឹងថា ក្រោយបើកការស៊ើបអង្កេតនិងនាំខ្លួនមកសាកសួរ ជនសង្ស័យប្រុសស្រីទាំង២នាក់បងប្អូនបង្កើតត្រូវបានរកឃើញថា បានប្រព្រឹត្តបទល្មើសជួញដូរមនុស្សឆ្លងដែន និងបទក្លែងឯកសារ ហើយក៏ត្រូវបានតុលាការឃុំខ្លួនពួកគេទាំង២នាក់នៅពន្ធនាគារខេត្ត នារសៀលថ្ងៃទី២១ ខែកញ្ញា ។ ស្នងការរងនគរបាលទទួលបន្ទុកប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន លោកស្រីវរសេនីយ៍ឯក នៅ រតនា បានឲ្យដឹងថា ស្ត្រីរងគ្រោះអាយុ២១ឆ្នាំ ត្រូវជាក្មួយស្រីបង្កើតរបស់ជនសង្ស័យទាំង២នាក់ ដែលមានទីលំនៅក្នុងឃុំកំពង់ដំរី ស្រុកឆ្លូង បានរងគ្រោះដោយត្រូវពួកគេល្បួងយកទៅលក់ឲ្យបុរសជនជាតិចិននៅប្រទេសចិន តាមរយៈខ្សែបណ្តាញរបស់ពួកគេតាំងពីឆ្នាំ២០១៦ ។ លោកស្រីស្នងការរងបន្តថា ក្មួយស្រីម្នាក់នេះបានរងគ្រោះដោយសារពួកគេជួញដូរទៅលក់ឲ្យបុរសជនជាតិចិនចំនួន២ដង ។

រហូតមកទល់នឹងពេលនេះ ស្ត្រីរងគ្រោះមានកូនក្នុងពោះចំនួន៨ខែ និងត្រូវបានបញ្ជូនមកស្រុកកំណើតវិញកាលពីពាក់កណ្តាលឆ្នាំ២០១៨ ។ជនសង្ស័យប្រុសស្រីជាបងប្អូនបង្កើតទាំង២នាក់នេះ ម្នាក់ឈ្មោះ ពៅ សារ៉ាត់ ភេទប្រុស អាយុ៤៦ឆ្នាំ និងម្នាក់ទៀតឈ្មោះ ពៅ ចិន្តា ភេទស្រី អាយុ៥៥ឆ្នាំ ។ ពួកគេទាំង២នាក់ត្រូវជាបងប្អូនបង្កើតជាមួយម្តាយស្ត្រីរងគ្រោះ។ប្រភពពីនគរបាលបានឲ្យដឹងទៀតថា កាលពីឆ្នាំ២០១៦ ពួកគេបានល្បួងស្ត្រីរងគ្រោះយកទៅលក់ឲ្យបុរសជនជាតិចិន នៅប្រទេសចិនតាមរយៈខ្សែបណ្តាញរបស់ពួកគេនៅប្រទេសចិន។មិនតែប៉ុណ្ណោះ ពួកគេថែមទាំងបានក្លែងឯកសារមួយចំនួន សម្រាប់សម្រួលដល់ការឆ្លងដែនរបស់ស្ត្រីរងគ្រោះទៀតផង ។ ពេលទៅដល់ប្រទេសចិន នាងត្រូវបានបង្ខំឲ្យយកប្តីជនជាតិចិន និង រងការវាយធ្វើបាបពីប្តីជនជាតិចិន ហើយនាងបានរត់គេចតែក៏ត្រូវពួកគេលក់បន្តទៅឲ្យបុរសជនជាតិចិនម្នាក់ផ្សេងទៀត ។

ដោយសារការអត់ទ្រាំនឹងការវាយធ្វើបាបពីសំណាក់ប្តីជាជនជាតិចិនលើកក្រោយនេះមិនបាន នាងក៏បានរត់ទៅរកអាជ្ញាធរឲ្យជួយហើយក៏ត្រូវបានអាជ្ញាធរចាត់បញ្ជូនមកស្រុកវិញ ។ នគរបាលបានឲ្យដឹងទៀតថា ក្នុងអំឡុងពេលជាង២ឆ្នាំដែលស្ត្រីរងគ្រោះត្រូវជនសង្ស័យជួញដូរឲ្យទៅយកប្តីចិននៅក្រៅប្រទេស នាងមិនបានប្រាក់កម្រៃអ្វីនោះទេ ដោយសារលុយទាំងអស់ត្រូវបានជនសង្ស័យទាំង២នាក់បងប្អូនកេងប្រ វ័ញ្ចយកអស់ ។ អ្វីដែលគួឲ្យអាសូរនោះគឺចុងក្រោយស្ត្រីរងគ្រោះគ្មានសល់អ្វីក្រៅពីកូននៅក្នុងពោះដែលនឹងជិតគ្រប់ខែដោយគ្មានអ្នកទទួលខុសត្រូវ៕

# ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨

## អាជីវកម្មផ្លូវភេទ ប្តូររូបភាពពីចំហរ មកលួចលាក់ ជ្រកក្រោម រូបភាពស្របច្បាប់ គឺកន្លែង ម៉ាស្សា

https://www.dap-news.com/ ByID:112 Posted on September Tue, 2018 16:04

ភ្នំពេញ ៖ លោក ប៉ុល ភិធេយ្យ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរ និងការពារអនីតិជន បានបញ្ជាក់ថា អាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ បានប្តូររូបភាព ពីចំហរមកជាការលួចលាក់ ជ្រកក្រោមរូបភាព ស្របច្បាប់ដូចជា ហាងម៉ាស្សា កោសជប់ ,ខារ៉ាអូខេ ,ហាងលក់កាហ្វេ ,ហាងអ៊ុតសក់ ,ផ្ទះសំណាក់ ,សណ្ឋាគារ ជាដើម។ នេះបើយោងតាមអគ្គស្នងការដ្ឋាននគរបាលជាតិ។

ក្នុងកម្មវិធី វគ្គបណ្តុះបណ្តាល ស្តីពីយុទ្ធវិធីប្រតិបត្តិការ និងការប្រើប្រាស់អាវុធ នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០១៨ លោក ប៉ុល ភិធេយ្យ បានថ្លែងថា ពាក់ព័ន្ធទៅនឹងស្ថានភាព បទល្មើស នៃការជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទស្ត្រី និងកុមារនៅកម្ពុជា បុរសស្ត្រីពេញវ័យមួយចំនួន ត្រូវបានគេនាំទៅធ្វើការខុសច្បាប់នៅក្រៅប្រទេស ពិសេសប្រទេសថៃ មួយចំនួន ត្រូវបានគេលក់ឲ្យម្ចាស់ទូកនេសាទសមុទ្រ ស្ត្រីពេញវ័យមួយចំនួនទៀត ត្រូវបានគេលួងលោម បោកបញ្ឆោតយកទៅរៀបអាពាហ៍ពិពាហ៍ជាមួយបុរសជនជាតិ ចិនផ្ទុយពីឆន្ទៈ។

លោក ប៉ុល ភិធេយ្យ មានប្រសាសន៍ថា "អាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ បានប្តូររូបភាពពី ចំហរ មកជាការលួចលាក់ ហើយជ្រកក្រោមរូបភាពស្របច្បាប់ដូចជា ហាងម៉ាស្សាកោសជប់ ខារ៉ាអូខេ ហាងលក់កាហ្វេ ហាងអ៊ុតសក់ ផ្ទះសំណាក់ និងសណ្ឋាគារ ហើយបាន ប្តូរពីទី ប្រជុំជនទៅតំបន់ជាយរាជធានីភ្នំពេញ និងខេត្តកណ្តាល រួមទាំងបណ្តាខេត្តជាប់ព្រំដែន ដែលមានជីវភាពរីកចម្រើន"។ លោកបន្តថា ចំពោះស្ត្រីពេញវ័យមួយចំនួន ត្រូវបានមេខ្យល់នាំពីជនបទមកទីក្រុង ដើម្បីរក ការងារធ្វើ រួចលួងលោមយក ទៅជួញដូរនិងធ្វើអាជីវកម្មលើផ្លូវភេទ៕ ដោយ អេង ប៊ូឆេង

## នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បើកវគ្គបណ្តុះបណ្តាលស្តីពី យុទ្ធវិធីប្រតិបត្តិការ និងការប្រើប្រាស់អាវុធ

http://cambodiapolice.com/policekh/ 1:49 pm 25 កញ្ញា 2018

ភ្នំពេញ ៖ នាព្រឹកថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨នេះ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន មានបើកវគ្គបណ្តុះបណ្តាលស្តីពីយុទ្ធវិធីប្រតិបត្តិការ និងការប្រើប្រាស់អាវុធ ក្រោមអធិបតីភាព ឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ ប្រធាននាយកដ្ឋានប្រឆាំងការ ជួញដូរនិងការពារអនីតិជន តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ និងដោយមានលោក អេរិច មេលឌ្រីម នាយកផ្នែកស៊ើបអង្កេតនៃអង្គការមេត្រីអន្តរជាតិ (AIMSWAT) , លោក រ៉ូប៊ឺត ស្តេតុន នាយកបណ្តុះបណ្តាលប៉ូលីសអន្តរជាតិ ប្រតិបត្តិការយុទ្ធវិធីនិងប្រឆាំង ភេរវកម្ម ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរ និងការពារអនីតិជន បានមានប្រសាសន៍ថា ពាក់ព័ន្ធទៅនឹងស្ថានភាពបទល្មើសនៃការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទស្ត្រី និងកុមារនៅកម្ពុជា បុរសស្ត្រីពេញវ័យមួយចំនួន ត្រូវបានគេនាំទៅធ្វើការខុសច្បាប់នៅក្រៅប្រទេស ពិសេសប្រទេសថៃ ហើយមួយចំនួនត្រូវបានគេលក់ឲ្យម្ចាស់ទូកនេសាទសមុទ្រ ស្ត្រីពេញវ័យមួយចំនួនទៀត ត្រូវបានគេលួងលោម បោកបញ្ឆោតយកទៅរៀបអាពាហ៍ពិពាហ៍ជាមួយបុរសជនជាតិចិនផ្ទុយពីឆន្ទៈ ។ ឯកឧត្តមឧត្តមសេនីយ៍ឯកប្រធាននាយកដ្ឋាន បានមានប្រសាសន៍បន្តទៀតថា អាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ បានប្តូររូបភាពពីចំហរមកជាការ

លួចលាក់ ហើយជ្រកក្រោមរូបភាពស្របច្បាប់ដូចជា ៖ ហាងម៉ាស្សាកោសដប់ ខារ៉ាអូខេ ហាងលក់កាហ្វេ ហាងអ៊ុតសក់ ផ្ទះសំណាក់ និងសណ្ឋាគារ ហើយបាន ប្តូរពីទីប្រជុំជនទៅតំបន់ជាយរាជធានីភ្នំពេញ និងខេត្តកណ្តាល រួមទាំងបណ្តាខេត្តជាប់ព្រំដែនដែលមានជីវភាពរីកចម្រើន ។ ចំពោះស្ត្រីពេញវ័យមួយចំនួនត្រូវបានមេខ្យល់នាំពីជនបទមកទីក្រុង ដើម្បីរកការងារធ្វើ រួចលួងលោមយកទៅជួញដូរនិងធ្វើអាជីវកម្មលើផ្លូវភេទ ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ បានបន្តទៀតថា តាមរយៈវគ្គបណ្តុះបណ្តាលនាពេលនេះ ឯកឧត្តមជឿជាក់ថា សិក្ខាកាមពិតជាទទួលបានចំណេះដឹងបទពិសោធន៍ថ្មីៗបន្ថែមទៀត ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការបង្ក្រាបចាប់ជនសង្ស័យបញ្ជូនទៅតុលាការ និងជួយសង្គ្រោះជនរងគ្រោះបានទាន់ពេលវេលា ។ ការហ្វឹកហាត់នេះ ផ្តើមចេញពីគ្រូឧទ្ទេសនាមដែលមានបទពិសោធន៍ ក្នុងការអនុវត្តបំពេញភារកិច្ចនៅសហរដ្ឋអាមេរិក និងមានគ្រូជំនួយជាស្ត្រីចំនួន២រូប មកពីនាយកដ្ឋាន០១រូប និងស្នងការដ្ឋាននគរបាលខេត្តកណ្តាល០១រូប ។

សូមបញ្ជាក់ថា វគ្គបណ្តុះបណ្តាលនេះ មានរយៈពេល៣ថ្ងៃ គឺចាប់ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ ដោយមានសិក្ខាកាមចូលរួម ចំនួន២០រូប មកពីនាយកដ្ឋាន០៥រូប , ស្នងការដ្ឋានរាជធានីភ្នំពេញ០៥រូប , ស្នងការដ្ឋានខេត្តត្បូងឃ្មុំ១រូប , ស្នងការដ្ឋានខេត្តបន្ទាយមានជ័យ០១រូប , ស្នងការដ្ឋានខេត្តព្រះសីហនុ០២រូប , ស្នងការដ្ឋានខេត្តកំពង់ធំ២ រូប, ស្នងការដ្ឋានខេត្តសៀមរាប០២រូប និងស្នងការដ្ឋានខេត្តបាត់ដំបង ០២រូប ៕

## គ្រួសារមួយ ថ្លែងពីទុក្ខសោក ក្រោយកូនស្រីរៀបការប្តីចិន

https://www.postkhmer.com/ ដោយ គង់ មេត្តា | Publication date 25 September 2018 | 14:02 ICT

**ភ្នំពេញៈ** ធី ជាឈ្មោះដែលត្រូវបានបង្កើតឡើងដើម្បីការពារអត្តសញ្ញាណខណៈគ្រួសារគាត់បានឆ្លងកាត់នូវដំណើររឿងសោកសៅពីការជំពាក់វ៉ាក់វិននឹងបំណុលគេ រហូតឈានដល់ដាច់ចិត្តឱ្យកូនស្រីវ័យក្មេងរៀបការប្តីចិនដោយនឹកស្មានថាអាចបានប្រាក់មកលោះបំណុល តែមិនបានដូចបំណងបែរជាទៅជួបគ្រោះមួយជាន់ទៀតគួរឱ្យសោកស្តាយ។

អ្នកស្រី ធី មានអាយុ ៣០ ឆ្នាំគាត់មានកូន ៣ នាក់។ ខុសពីសព្វមួយដងកាលពីដើមឆ្នាំនេះអ្នកស្រី ធី បានភ្ញាក់ពីព្រលឹមម៉ោង ៥ ព្រឹកពីព្រោះគាត់ និងក្រុមគ្រួសារត្រូវរត់គេចពីភូមិកំណើតដោយសារតែគ្មានលទ្ធភាពសងប្រាក់កម្ចីដែលគាត់ជំពាក់មីក្រូហិរញ្ញវត្ថុ។ អ្នកស្រីបានធ្វើដំណើរតាមរថយន្តតាក់ស៊ីពីស្រុកចំការលើខេត្តកំពង់ចាមទៅកាន់ខេត្តរតនគិរីដើម្បីធ្វើការជាអ្នកដកជំឡូងមីជាមួយស្វាមី និងកូនស្រីច្បងកាលពីខែកុម្ភៈឆ្នាំនេះ។ អ្នកស្រី ធី បានរំឭកអំពីដំណើររឿងនៃការធ្លាក់ខ្លួនជំពាក់លុយមីក្រូហិរញ្ញវត្ថុហើយមិនមានលទ្ធភាពសងបំណុលវិញថា៖ «ខ្ញុំជំពាក់លុយមីក្រូហិរញ្ញវត្ថុច្រើនដោយខ្ញុំមិនមានលុយសងបំណុលទេ។ ពីដំបូងខ្ញុំជំពាក់ប្រហែល ២០០០ ដុល្លារ ប៉ុន្តែដោយសារតែខ្ញុំមិនអាចសងវិញបាន ដូច្នេះខ្ញុំបានខ្ចីពីអ្នកចងការប្រាក់ក្រៅផ្លូវការដែលមានប្រហែល១០ កន្លែង ដើម្បីយកទៅបង់រំលស់ថ្លៃជំពាក់លុយមីក្រូហិរញ្ញវត្ថុ ខ្លះប៉ុន្តែការប្រាក់ចេះតែកើនឡើង»។ អ្នកស្រីរៀបរាប់ថា៖ «យើងបានខ្ចីប្រាក់ពីមីក្រូហិរញ្ញវត្ថុ ពីព្រោះពេលនោះយើងមិនមានដីផ្ទាល់ខ្លួនសម្រាប់រស់នៅ។ ពេលនោះស្រាប់តែមានគេលក់ដី ដូច្នេះខ្ញុំក៏ទៅខ្ចីប្រាក់ហើយយើងក៏បានទិញដីនោះសង់ខ្ទមរស់នៅ»។ ប្រភពចំណូលរបស់អ្នកស្រី ធី និងស្វាមីគឺបានមកពីការស៊ីឈ្នួលដកជំឡូងមីគឺមានប្រមាណ ៥ ដុល្លារក្នុង ១ ថ្ងៃ។ ប៉ុន្តែវាមិនមែនជាចំណូលដែលមានស្ថិរភាពនោះទេ។ អ្នកស្រីបានបន្តថា៖ «នៅពេលពួកយើងរស់នៅទីនោះយើងធ្វើជាកម្មករដកជំឡូងមីដែលយើងអាចរកកម្រៃបានប្រមាណ ៥ ដុល្លារក្នុង ១ ថ្ងៃ។ បើសរុបយើងទាំង ៣ នាក់អាចរកប្រាក់បាន ៣ ម៉ឺនរៀល ប៉ុន្តែអង្ករថ្លៃណាស់ទីនោះជាតំបន់ដាច់ស្រយាល ហើយម្ហូបអាហារក៏ថ្លៃដែរពួកយើងអាចមានលទ្ធភាពត្រឹមទិញពងមាន់ទទួលទានប៉ុណ្ណោះ»។

ប៉ុន្តែជាអកុសលបន្ទាប់ពីផ្លាស់ទៅរស់នៅកន្លែងថ្មីដើម្បីគេចចេញពីការសងបំណុលបាន ១ ខែកន្លះ ស្រាប់តែម្តាយមីងអ្នកស្រី ធី បានប្រាប់ថា ផ្ទះរបស់គាត់កំពុងត្រូវបានមីក្រូហិរញ្ញវត្ថុដាក់លក់កាលពីខែមេសា បន្ទាប់ពីចូលឆ្នាំខ្មែរ។ អ្នកស្រីបានបញ្ជាក់ថា៖ «នៅពេលល្ងាច បន្ទាប់ពីញ៉ាំបាយរួចម្តាយមីងខ្ញុំបានប្រាប់ថា ផ្ទះរបស់ខ្ញុំត្រូវបានដាក់ស្លាកលក់គឺពួកគេនឹងលក់ផ្ទះខ្ញុំប្រសិនបើខ្ញុំគ្មានលទ្ធភាពសងប្រាក់ពួកគេទេ។ កូនស្រីរបស់ខ្ញុំឃើញខ្ញុំយំនាងក៏បានសួរខ្ញុំថា តើគាត់អាចទៅកន្លែងណាដើម្បីរកលុយសងបំណុលគេបាន? អ៊ីចឹងកូនខ្ញុំសុំខ្ញុំទៅប្រទេសចិនគឺទៅរៀបការជាមួយជនជាតិចិនប្រហែលជាមានលុយអាចសងបំណុលគេបាន។ នៅពេលនោះកូនខ្ញុំទើបមានអាយុ ១៤ ឆ្នាំប៉ុណ្ណោះ ដូច្នេះត្រូវរង់ចាំច្រើនឆ្នាំទៀតដើម្បីឱ្យគាត់គ្រប់អាយុ ប៉ុន្តែកូនខ្ញុំចង់ទៅភ្លាមៗ»។ លោកស្រី ធី និងកូនស្រីបានពិភាក្សាគ្នាអំពីរឿងនេះអស់រយៈពេល ២ ថ្ងៃរហូតដល់ទៅនិយាយជាមួយសាច់ញាតិរបស់មេខ្យល់។ សាច់ញាតិនោះបានជួយទាក់ទងស្ត្រីដែលជាជនសង្ស័យម្នាក់ឈ្មោះ ផន សុខណេង មានអាយុ ២១ ឆ្នាំដែលបច្ចុប្បន្នកំពុងជាប់ឃុំបណ្តោះអាសន្ននៅពន្ធនាគារខេត្តកំពង់ចាម ក្រោយចាប់ខ្លួននៅថ្ងៃ ១៣ កញ្ញាឆ្នាំនេះ។ នេះបើតាមរបាយការណ៍ក្នុងគេហទំព័រនគរបាលជាតិ។ ស្ត្រីឈ្មោះ ណេង កាលពីមិនទាន់ត្រូវបានចាប់ខ្លួនបានផ្ញើដំណឹងថាអ្នកស្រី ធី ថានឹងអាចទទួលបានប្រាក់ ២ ៥០០ ដុល្លារពេលកូនអ្នកស្រីបានរៀបការជាមួយបុរសចិនដោយជោគជ័យ។ នៅថ្ងៃបន្ទាប់ឈ្មោះ ណេង បានផ្ញើប្រាក់ជូនអ្នកស្រី ធី ៥០ ដុលារដើម្បីជាសោហ៊ុយឱ្យអ្នកស្រី ធី និងកូនព្រមទាំងសាច់ញាតិធ្វើដំណើរមកភ្នំពេញដើម្បីធ្វើលិខិតឆ្លងដែន។

អ្នកស្រីថ្លែងថា៖ «បន្ទាប់មកខ្ញុំបាននិយាយថ្លៃជាមួយពួកគេហើយពួកគេបានប្រាប់យើងថា ពួកគេអាចដំឡើងឲ្យបានថ្លៃរហូតដល់ ២៦០០ ដុល្លារ។ កូនស្រីខ្ញុំបានប្រាប់ខ្ញុំមិនឱ្យចរចាតម្លៃជាមួយពួកគេទេដោយសង្ឃឹមថាអាចសន្សំប្រាក់ខ្លះទុកសងគេ ហើយយើងបានពិភាក្សាគ្នាអស់ ២ ថ្ងៃ»។ នៅពេលគ្រួសារអ្នកស្រី ធី និងសាច់ញាតិមកដល់ភ្នំពេញ អ្នកស្រី ធី បានប្រាប់ថាស្ត្រីឈ្មោះ ណេង បានផ្តល់ដំណឹងថានឹងមានស្ត្រីរូបស្អាតម្នាក់មកទទួលឱ្យទៅស្នាក់នៅផ្ទះសំណាក់។ អ្នកស្រី ធី បន្ថែមថា៖ «នៅពេលយើងមកដល់ផ្ទះសំណាក់ភ្លាម [ស្ត្រីស្អាត] នោះបានឱ្យកូនស្រីរបស់ខ្ញុំក្រោកឈរដើម្បីថតរូប...ហើយពិនិត្យមើលឯកសារដូចជាសំបុត្រកំណើតកូនស្រីរបស់ខ្ញុំ និងអាសយដ្ឋាន ហើយបានប្រាប់ពួកយើងថាប្រហែលមិនអាចធ្វើបានទេ។ ប៉ុន្តែបានប្រាប់យើងថា កុំឱ្យចាកចេញពីផ្ទះសំណាក់គឺរង់ចាំរហូតដល់ជួបស្ត្រីឈ្មោះ ណេង។ អ្នកស្រី ធី ថ្លែងថាបន្ទាប់ពីស្នាក់នៅផ្ទះសំណាក់ ១ យប់ពួកគាត់ក៏ត្រឡប់ទៅខេត្តរតនគិរីវិញដោយទទួលបានលុយ ៥០ ដុល្លារចែកគ្នាជាមួយសាច់ញាតិ ហើយជនសង្ស័យឈ្មោះ ណេង បានប្រាប់គាត់ថាកុំឲ្យបារម្ភពីកូនស្រី។ អ្នកស្រីបន្តថា៖ «ពេលនោះខ្ញុំមិនបានយកកូនស្រីរបស់ខ្ញុំមកវិញទេគឺនាងបាននៅផ្ទះសំណាក់ជាមួយស្ត្រីឈ្មោះ ណេង ហើយគេប្រាប់ខ្ញុំថាកុំឲ្យបារម្ភពីកូនស្រី។ គាត់ថានឹងជួយកូនស្រីខ្ញុំឱ្យបានរៀបការជាមួយប្តីចិនអ្នកមាន។ ១ សប្តាហ៍ក្រោយមកកូនស្រីខ្ញុំបានប្រាប់ខ្ញុំថា នាងបានធ្វើលិខិតឆ្លងដែនរួចហើយ តែថានាងមិនទាន់អាចចេញទៅចិនបានភ្លាមទេ គឺត្រូវរង់ចាំស្ត្រី ២-៣ នាក់ផ្សេងទៀតទៅជាមួយដែរ។ ខ្ញុំមានអារម្មណ៍សោកស្តាយណាស់ដែលខ្ញុំមិនបាននិយាយពាក្យលាទៅកាន់កូនខ្ញុំ។ ខ្ញុំសោកស្តាយដែលខ្ញុំមិនបានជូនដំណើរកូនចុងក្រោយ»។

បន្ទាប់ពីកិច្ចព្រមព្រៀងត្រូវបានធ្វើរួចរាល់ក្រោយមកទៀតអ្នកស្រី ធី បានទទួលដំណឹងពីកូនស្រីកាលពីខែឧសភាថា នាងទៅដល់ប្រទេសចិនហើយ។ អ្នកស្រីថា៖ «ពេលនាងទៅដល់ចិនបាន ១ សប្តាហ៍នាងបានទូរស័ព្ទមកខ្ញុំតាមរយៈលេខថៅកែរបស់នាងថានាងបានមកដល់ប្រទេសចិនហើយគឺកំពុងរង់ចាំកូនកំលោះមកជួប»។ នាងប្រាប់ខ្ញុំថា៖ «ខ្ញុំនឹងប្រាប់ថៅកែឲ្យផ្ញើលុយមក ហើយ ២-៣ ថ្ងៃក្រោយមកស្ត្រីឈ្មោះ ណេង បានផ្ញើលុយឲ្យខ្ញុំចំនួន ២១០០ ដុល្លារ»។ បន្ទាប់ពីទទួលបានលុយ ១ សប្តាហ៍អ្នកស្រី ធី បានទទួលដំណឹងថា កូនស្រីត្រូវបានគេផ្គូផ្គងជាមួយប្តីចិន ហើយនាងសុខសប្បាយទេគឺដឹងតាមរយៈឈ្មោះ ណេង។ ប៉ុន្តែតាមព័ត៌មានដែលអ្នកស្រី ធី ដឹងពីកូន

ស្រីគឺថានាងមិនបានសុខទេនៅពេលនាងខលប្រាប់តាម (wechat) កាលពីខែមិថុនាដោយថា ក្នុង ១ ថ្ងៃគេឲ្យញុំាអាហារតែម្តងប៉ុណ្ណោះជាមួយនឹងការធ្វើកិច្ចការសព្វសារពើគឺជូតសម្អាតផ្ទះ ៤ ជាន់ ទៅជូតសម្អាតមន្ទីរពេទ្យជាកន្លែងដែលម្តាយក្មេកធ្វើការរួមនឹងធ្វើការងារច្រើនមុខទៀត។ អ្នកស្រីបញ្ជាក់ថា៖ «ពេលវាបានទូរស័ព្ទមកខ្ញុំកូនស្រីបានប្រាប់ខ្ញុំថា វាពិបាករស់នៅណាស់រួចក៏យំ។ ប្តីរបស់នាងបានគេងជាមួយនាងទាំងថ្ងៃទាំងយប់សូម្បីពេលនាងមករដូវ។ ពីដំបូងខ្ញុំបានប្រាប់កូនឱ្យអត់ធ្មត់ពីព្រោះខ្ញុំគិតថាបើប្រើទូរស័ព្ទច្រើនពេកប្តីរបស់នាងអាចរឹបអូសទូរស័ព្ទឈប់ឲ្យប្រើ»។

យ៉ាងណាក្តីអ្នកស្រីថា៖ «ខ្ញុំមិនបានដាក់ពាក្យបណ្តឹងទៅប៉ូលិសភ្លាមៗទេបន្ទាប់ពីកូនស្រីរបស់ខ្ញុំបានប្រាប់ពីការលំបាកណាស់។ ក្រោយមកខ្ញុំព្យាយាមទាក់ទង ប៉ុន្តែប្តីនាងបានរឹបអូសទូរស័ព្ទ។ បន្ទាប់មកខ្ញុំព្យាយាមខលទៅថៅកែនាង ប៉ុន្តែទាក់ទងមិនបាន»។ បន្ទាប់មកអ្នកស្រី ធី បានទទួលការហៅទូរស័ព្ទពីស្ត្រីខ្មែរម្នាក់នៅទីនោះដោយបានប្រាប់ថា កូនស្រីអ្នកស្រីបានរត់ចេញពីផ្ទះប្តីនាងហើយ ហើយបានផ្ញើរូបនាងឱ្យមើលឃើញមានស្នាមជាំនឹងមុខធ្វើឱ្យអ្នកស្រីរន្ធត់។ អ្នកស្រី ធី ថា៖ «ខ្ញុំមិនដែលវាយដំកូនខ្ញុំទេ។ នៅពេលខ្ញុំបានឃើញស្នាមរបួសក្នុងរូបភាពខ្ញុំស្ទើរតែសន្លប់»។ លុះដល់កាលពីខែសីហាអ្នកស្រី ធី បានទទួលទូរស័ព្ទពីស្ត្រីខ្មែរម្នាក់គំរាមទារប្រាក់អ្នកស្រី ២ ម៉ឺនដុល្លារដោយប្រាប់ថា កូនអ្នកស្រីបានរត់គេចពីផ្ទះប្តី ហើយមិនព្រមទទួលយកប្តីថ្មី។ អ្នកស្រី ធី ថា៖ «ស្ត្រីខ្មែរបានទូរស័ព្ទប្រាប់ខ្ញុំថា ប្រសិនបើខ្ញុំមិនប្រគល់លុយឱ្យ គេនឹងលក់កូនខ្ញុំទៅឱ្យផ្ទះបន»។ ជាមួយគ្នានេះអ្នកស្រី ធី បានរៀបរាប់ដែរថាក្នុងភូមិរបស់គាត់មានស្ត្រីជាច្រើនបានរៀបការជាមួយបុរសជនជាតិចិនតាមរយៈមេខ្យល់។ អ្នកស្រីថា៖ «ខ្ញុំងាយជឿគេណាស់ដោយសង្ឃឹមថាគេអាចស្វែងរកស្វាមីមានទ្រព្យឲ្យកូនខ្ញុំបានដោយមិនបានគិតថា ពួកគេលក់កូនស្រីខ្ញុំទេ។ បើខ្ញុំដឹងខ្ញុំនឹងមិនអនុញ្ញាតឱ្យវាទៅទេ»។

ទាក់នឹងករណីស្រដៀងគ្នានេះដែរកាលពីថ្ងៃទី ២១ ខែកញ្ញាឆ្នាំនេះ ជនសង្ស័យប្រុសស្រី ២ នាក់ត្រូវបានតុលាការខេត្តក្រចេះសម្រេចឃុំខ្លួន បន្ទាប់ពីសមត្ថកិច្ចឃាត់ខ្លួនពាក់ព័ន្ធនឹងករណីលក់ក្មួយស្រីបង្កើតឱ្យបុរសជនជាតិចិនប្រព្រឹត្តកាលពីឆ្នាំ ២០១៦។ នេះបើតាមលោកស្រី នៅ រតនា ស្នងការរងនគរបាលខេត្តក្រចេះ។ លោកស្រី នៅ រតនា បានបញ្ជាក់ថាជនសង្ស័យបានជួញដូរមនុស្សឆ្លងដែន និងក្លែងឯកសារ ដើម្បីយកស្ត្រីរងគ្រោះអាយុ ២១ ឆ្នាំជាក្មួយបង្កើតរបស់ខ្លួននៅឃុំកំពង់ដំរី ស្រុកឆ្លូងទៅលក់ឲ្យបុរសចិនតាមរយៈបណ្តាញ ពួកគេតាំងពី ២ ឆ្នាំមុន។ លោកស្រីបន្តថាបុរសសង្ស័យឈ្មោះ ពៅ សារ៉ាត់ អាយុ ៤៦ ឆ្នាំ និងស្ត្រីឈ្មោះ ពៅ ចិន្តា អាយុ ៥៥ ឆ្នាំ។ ពួកគេជាបងប្អូនបង្កើតនឹងម្តាយនារីរងគ្រោះ។ លោកស្រី រតនា ថា៖ «នាងរងគ្រោះត្រូវជនសង្ស័យយកទៅលក់ឲ្យបុរសជនជាតិចិន ២ ដងរហូតមានផ្ទៃពោះ ៨ ខែ និងត្រូវបញ្ជូនមកស្រុកកំណើតវិញកាលពីពាក់កណ្តាលឆ្នាំនេះ»។ លោកស្រីបន្ថែមថា ខណៈនៅប្រទេសចិន នារីរងគ្រោះត្រូវបានបង្ខំឲ្យយកប្តីចិន និងរងការវាយធ្វើបាបពីប្តីហើយនៅពេលនាងរត់គេចត្រូវពួកគេចាប់បានយកលក់បន្តទៅឲ្យបុរសចិនម្នាក់ទៀត។ ដោយអត់ទ្រាំនឹងការវាយធ្វើបាបពីប្តីចិនទី ២ មិនបាន នាងបានរត់ទៅរកគេជួយហើយក៏ត្រូវបានអាជ្ញាធរចិនចាប់បញ្ជូនមកស្រុកខ្មែរវិញ។ លោកស្រីបញ្ជាក់ថា៖ «អ្វីដែលគួរឲ្យអាសូរនោះគឺចុងក្រោយនារីរងគ្រោះគ្មានសល់អ្វីក្រៅពីមានកូនក្នុងពោះដែលជិតគ្រប់ខែដោយគ្មានអ្នកទទួលខុសត្រូវឡើយ...»។

ជុំវិញករណីនេះបើតាមរបាយការណ៍៦ ខែឆ្នាំមុនគឺមានស្ត្រី ២២ នាក់ត្រូវបានបញ្ជូនមកពីប្រទេសចិនវិញ។ អ្នកនាំពាក្យក្រសួងការបរទេសមិនអាចទាក់ទងដើម្បីសុំការបំភ្លឺបានទេ។

ប៉ុន្តែតាមសេចក្តីរាយការណ៍របស់ភ្នំពេញប៉ុស្តិ៍គិតត្រឹមខែសីហានៅឆ្នាំនេះថាមានស្ត្រីចំនួន ៧ នាក់ហើយត្រូវបានគេបញ្ជូនត្រឡប់មកពីប្រទេសចិនវិញ៕ NS **រាយការណ៍បន្ថែមដោយ សុទ្ធ គឹមសឿន**

## ទីតាំងម៉ាស្សាបង្កប់សេវាផ្លូវភេទ របស់ជនជាតិចិន បើកយ៉ាងអាណាធិបតេយ្យ ក្នុងក្រុងព្រះសីហនុ ជួយស៊ែរឲ្យអាជ្ញាធរ និងមន្ត្រីដែលពាក់ពន្ធ័បានឃើញផង

https://khmernews.news/article/archives/ 25-09-2018 វាសនា

ក្រុងព្រះសីហនុ: ប្រជាពលរដ្ឋរស់នៅក្នុងក្រុងព្រះសីហនុ បានផ្ញើវីឌីអូនិងរូបភាពជាច្រើនសន្លឹកអោយជួយផ្សាយទីតាំងម៉ាស្សាបង្កប់សេវាកម្មផ្លូវភេទរបស់ជនជាតិចិនបើកដំនើរការជាច្រើនផ្ទះក្បែរៗគ្នា ដោយមិនរញ៉េតខ្លាចនិងសមត្ថកិច្ចឡើយបង្ករការរំខានដល់ពួកគាត់រស់នៅក្បែរនោះជារៀងរាល់យប់។ ទីតាំងម៉ាស្សាបង្កប់សេវាកម្មផ្លូវភេទនេះតាមស្ថិតនៅតាមបណ្តោយផ្លូវចំការស្លែ ក្រុងព្រះសីហនុ។ ប្រជាពលរដ្ឋសំណូមពរដល់អជ្ញាធរ និងមន្ត្រីដែលពាក់ពន្ធ័ ជួយមានវិធានការណ៏ចំពោះទីតាំងខាងលើ អោយបានឆាប់រហ័សផង។ Help_Share_អោយអជ្ញាធរនិងមន្ត្រីដែលពាក់ពន្ធ័បានឃើញផង!!!!! អរគុណ ៕

## *ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨*

## សមមុខណាស់! បោគេយកទៅលក់ ស្មានពុំដល់ថា ព្រោះចិត្តលោភលន់ ចុងក្រោយត្រូវគេលក់វិញ!

http://www.cen.com.kh/archives/ September 26, 2018

ករណីជួញដូរមនុស្សដែលលំបាកជឿ តែមានពិតបានកើតឡើងនៅប្រទេសចិនកាលពី៥ឆ្នាំមុន ។ វាកាន់តែបង្កការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលដែលព័ត៌មានលំអិតនៃរឿងនេះត្រូវបានទម្លាយចេញតាមរលកទូរទស្សន៍ ។ ស្ថានីយ៍ទូរទស្សន៍រដ្ឋចិន ទើបបញ្ចាំងផ្សាយពីករណីជួញដូរមនុស្សដ៏កម្រមានបែបនេះ តែវាបានកើតឡើងនៅឆ្នាំ២០១៣ អមជាមួយដំណើររឿងបត់បែន ស្មានពុំដល់ ។ ព្រោះថា ក្រោយការទស្សនានោះ សំណួរដ៏សាមញ្ញមួយបានផ្ទុះនូវចម្លើយផ្សេងៗគ្នា ៖ តើអ្នកណាជាជនរងគ្រោះក្នុងករណីជួញដូរមនុស្សនេះ?

៥ ឆ្នាំមុនសិស្សវិទ្យាល័យម្នាក់ឈ្មោះ Liu Tue បានឡើងមកលេងនៅទីក្រុង តាមផ្លូវវិលត្រឡប់ទៅផ្ទះវិញនាងត្រូវគេលួចបាត់កាបូបលុយ ។ ឆ្លៀតឱកាសឃើញបែបនេះ ជនជួញដូរមនុស្សឈ្មោះ Liu Mai បានធ្វើពុតជាឈឺឆ្អាល សួរនាំ ហើយថែមទាំងប្រាប់ Liu Tue ថា ផ្ទះរបស់នាងនៅជិតផ្ទះរបស់ Liu Tue ដែរ ។ បន្ទាប់មកក៏ធ្វើពុតជា "មនុស្សល្អ" ទិញសំបុត្ររថយន្ត ២ ដើម្បីវិលទៅស្រុកទាំងអស់គ្នា ។ ទៅដល់ស្ថានីយ៍មួយ Liu Mai បានបបួល Liu Tue ឲ្យចូលផ្ទះរបស់ពូខ្លួនលេងសិន ។ Liu Tue គិតថា នៅមួយកំណាត់ផ្លូវឆ្លងភ្នំទៀតទើបដល់ផ្ទះ ហើយក្នុងហោប៉ៅពុំមានលុយមួយយាន់ផង ក៏ងក់ក្បាលយល់ព្រមទៅតាម Liu Mai ។ ប៉ុន្តែពេលដេកក្នុងបន្ទប់មួយដែល Liu Mai រៀបចំជាស្រេច ដោយចៃដន្យ Liu Tue បានស្តាប់ឮ Liu Mai កំពុងតថ្លៃលក់ខ្លួននាងឲ្យបុរសម្នាក់ ហើយចុងក្រោយពួកគេព្រមព្រៀងតម្លៃខ្លួននាងគឺ ៤០០០យាន់ (ប្រមាណ ៦០០ USD) ហើយសន្យាគ្នាថា ចាំយប់នឹងបញ្ជូននាងទៅឲ្យ ។

Liu Tue ធ្វើពុតជាដេកលក់មិនដឹងអ្វី ពេល Liu Mai ចូលមកបន្ទប់ នាងក៏ធ្វើពើនិយាយពីនេះពីនោះ រួចធ្វើជាឆ្លោយមាត់ប្រាប់ថា នាងមានមិត្តភក្តិ ៣នាក់ទៀត ចង់រកការងារធ្វើដើម្បីជួយដល់គ្រួសារ ។ Liu Mai កើតចិត្តលោភលន់ ចងលក់ម្តងទាំង៤នាក់ បានប្រាក់ច្រើនជាងក៏ឲ្យ Liu Tue ទៅផ្ទះ ហើយដេកនៅផ្ទះសំណាក់រង់ចាំ Liu Tue នាំមិត្តភក្តិមកឲ្យខ្លួន ។ Liu Tue ឆ្លៀតឱកាសនេះ គេចផុតពីកណ្តាប់ដៃ Liu Mai តែនាងកើតចិត្តចង់ "សងសឹក" តែបើទៅប្តឹងប៉ូលិសនោះនាងពុំមានភស្តុតាង ។

នៅតាមផ្លូវគេចចេញទៅ ចៃដន្យ Liu Tue បានជួបនឹងបុរសម្នាក់ពុំទាន់មានប្រពន្ធ ។ ក្រោយការសន្ទនាមួយសន្ទុះនាងក៏វិលមកជួប Liu Mai វិញ ហើយបបួល Liu Mai មកកាន់ផ្ទះបុរសនោះ ព្រោះនាងបានព្រមព្រៀង

លក់ Liu Mai ធ្វើជាប្រពន្ធបុរសនោះក្នុងតម្លៃ ៥០០យ៉ាន់ (ប្រមាណ ១៨០ USD) ។ Liu Tue វិលមកដល់ផ្ទះបានយំសោករំលឹករឿងរ៉ាវប្រាប់ឪពុកម្ដាយ ។ ឪពុកម្ដាយរបស់នាងបានទៅរាយការណ៍ប្រាប់ប៉ូលិស ។ ប៉ុន្តែពេលប៉ូលិសទៅដល់ផ្ទះបុរសនោះ ពុំឃើញស្រមោលរបស់ Liu Mai ។

តាមពិតទៅបុរសនេះក៏ជាជនជួញដូរមនុស្សដែរ ។ ហេតុនេះក្រោយពេលចាប់រំលោភ Liu Mai រួចវាបានលក់នាងទៅឲ្យបុរសម្នាក់ទៀតក្នុងភូមិ ។ ចុងក្រោយតុលាការកាត់ទោសឲ្យ Liu Mai ជាប់គុកមួយជីវិត ដោយសារមុននោះ នាងនេះបានលក់ក្មេង ៥-៦នាក់ទៀត ។ ពូរបស់នាង Liu Mai ជាប់គុក ១០ឆ្នាំ បុរសចាប់ Liu Mai រំលោភជាប់គុក ១៨ឆ្នាំ អ្នកទិញ Mai ជាប់គុក ១០ឆ្នាំ បុរសចាប់ Liu Tue ក៏ជាប់គុក ៣ឆ្នាំដែរ ។

ប៉ុន្តែម្ដាយឪពុករបស់ Liu Tue ពុំយល់ស្របនឹងការវិនិច្ឆ័យរបស់តុលាការ ក៏ពឹងពាក់មេធាវីសើរើក្ដីឡើងវិញ ។ ព្រោះតែ Liu Tue ពុំទាន់គ្រប់អាយុ ១៨ឆ្នាំ (នៅខ្វះប៉ុន្មានថ្ងៃ) ហើយទង្វើរបស់នាងផ្ដើមពីគំនិតសងសឹកប៉ុណ្ណោះ ពុំមែនដើម្បីលុយ ហើយដោយសារនាងរាយការណ៍ទើបជួយឲ្យប៉ូលិសចាប់បានជនជួញដូរមនុស្សដល់ទៅ ៤នាក់ តុលាការបានកាត់ឲ្យនាងរួចពីទោសទណ្ឌ ៕ ចន្ទ្រា

## ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨

### ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ ប្រាប់ឲ្យនគរបាលប្រឆាំងការជួញដូរយកចំណេះ ជំនាញ និងបទពិសោធន៍ ពីវគ្គបណ្ដុះបណ្ដាលទៅបម្រើអង្គភាពឲ្យមានប្រសិទ្ធ និងត្រូវចេះធ្វើការជាក្រុម

http://cambodiapolice.com/policekh/ 12:15 pm 28 កញ្ញា 2018

ភ្នំពេញ ៖ ប្រធាននាយដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ បានប្រាប់ឲ្យនគរបាលប្រឆាំងការជួញដូរយកចំណេះ ជំនាញ និងបទពិសោធន៍ ពីវគ្គបណ្ដុះបណ្ដាលទៅបម្រើអង្គភាពឲ្យមានប្រសិទ្ធ ជាពិសេសត្រូវចេះសហការគ្នាជាក្រុម ។ ក្នុងពិធីបិទវគ្គបណ្ដុះបណ្ដាលស្ដីពីយុទ្ធវិធីប្រតិបត្តិការ និងការប្រើប្រាស់អាវុធ នាព្រឹកថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨នេះ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ មានប្រសាសន៍ថា វគ្គបណ្ដុះបណ្ដាលនៅពេលនេះពិតជាបានផ្ដល់នូវចំណេះដឹង បទពិសោធន៍ថ្មីៗតាមរយៈ នៃការហ្វឹកហាត់ផ្ទាល់សំដៅរកភាពរីកចម្រើន និងសហប្រតិបត្តិការល្អក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ពិសេសការបង្ក្រាបបទល្មើសចាប់ជនសង្ស័យបញ្ជូនទៅតុលាការ និងជួយសង្គ្រោះជនរងគ្រោះបានទាន់ពេលវេលា ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ បន្តថា មន្ត្រីនគរបាលជំនាញដែលបាននឹងកំពុងបំពេញភារកិច្ចរក្សាសុវត្ថិភាព សន្តិសុខ និងសណ្ដាប់ធ្នាប់ ជូនប្រជាពលរដ្ឋចាំបាច់ត្រូវតែមានការស្វែងយល់បន្ថែមនូវវិធីសាស្ត្រការពារខ្លួនពេលប្រតិបត្តិការបង្ក្រាបបទល្មើស និងការប្រើប្រាស់អាវុធ ដាក់ស្ដែងពេលចាប់ជនសង្ស័យ និងសង្គ្រោះជនរងគ្រោះឲ្យបានទាន់ពេលវេលាប្រកបដោយសុវត្ថិភាព និងចេះសហការគ្នាជាក្រុម ។ ឯកឧត្តមប្រធាននាយដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បន្តទៀតថា ឆ្លងតាមកិច្ចសហប្រតិបត្តិការរវាងនគរបាលជាតិកម្ពុជាជាមួយអង្គការមេត្រីកម្ពុជា (AIMSWAT) កន្លងមកយើងពិនិត្យឃើញថា បទល្មើសជួញដូរមនុស្ស ពិសេសអំពើធ្វើអាជីវកម្មផ្លូវភេទលើអនីតិជនមានការប្រែប្រួលពីលក្ខណៈចំហមកជ្រកក្រោមរូបភាព ហាងម៉ាស្សា កោសជប់ ហាងកាត់សក់ និងខារ៉ាអូខេ ។ល។ ចំពោះជនរងគ្រោះជាអនីតិជន ដែលជ្រកក្រោមរូបភាពទាំងនេះ ត្រូវបាននាយកដ្ឋានសហការជាមួយអង្គការមេត្រីកម្ពុជា (AIMSWAT) ធ្វើការស្រាវជ្រាវស៊ើបអង្កេត និងបង្ក្រាបបានជាបន្តបន្ទាប់ ជាពិសេសយើងសង្កេតឃើញថា ក្នុងរយៈពេល៣ទៅ៤ឆ្នាំចុងក្រោយនេះ យើងទទួលបានចំណាត់ថ្នាក់លេខ២ ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ថ្វីត្បិតតែយើងមិនទាន់បានចំណាត់ថ្នាក់លេខ១ ក៏ប៉ុន្តែអ្វីដែលយើងទទួល

បានចំណាត់ថ្នាក់នេះ គឺបង្ហាញអំពីការប្រឹងប្រែងធន្ទ:របស់យើង ក៏ដូចជាកិច្ចសហប្រតិបត្តិការជាមួយមិត្តភក្តិអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល បើសិនជាគ្មានការប្រឹងប្រែងរបស់យើងទាំងអស់គ្នាទេ ក៏មិនមានចំណាត់ថ្នាក់ទី២នេះដែរ នេះអ្វីដែលយើងបានមើលឃើញទាំងអស់គ្នា ។

ក្នុងឱកាសនេះដែរ ឯកឧត្តមប្រធាននាយដ្ឋានប្រឆាំងការជួញដូរ និងការពារអនីតិជន តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោក អេរិច មេលទ្រឹម នាយកផ្នែកស៊ើបអង្កេតនៃអង្គការមេត្រីអន្តរជាតិ (AIMSWAT) , លោក រ៉ូបឺត ស្តេតុន នាយកបណ្តុះបណ្តាលប៉ូលីសអន្តរជាតិ ប្រតិបត្តិការយុទ្ធវិធីនិងប្រឆាំងភេរវកម្ម ដែលកន្លងមកតែងតែជួយឧបត្ថម្ភគាំទ្រដល់កងកម្លាំងនគរបាលជាតិកម្ពុជា តាមរយៈមេត្រីកម្ពុជា (AIMSWAT) ៕

## ឯកអគ្គរដ្ឋទូតចិនចប់អាណត្តិនៅកម្ពុជាអរគុណក្រសួងមហាផ្ទៃ ដែលបានបង្រ្កាបជនជាតិចិន ប្រព្រឹត្តិបទល្មើសបានទាន់ពេលវេលា

http://cambodiapolice.com/policekh/ 1:12 pm 28 កញ្ញា 2018 21

**ភ្នំពេញ ៖** ឯកឧត្តម ស្យុង ប៉ ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាមានិតចិនដែលចប់អាណត្តិនៅកម្ពុជា បានថ្លែងអំណរអគុណចំពោះសមត្ថកិច្ចក្រសួងមហាផ្ទៃ ដែលបានបង្រ្កាបរាល់ជនជាតិចិនដែលបានប្រព្រឹត្តិបទល្មើសបានទាន់ពេលវេលា ក្រោយពីជនជាតិចិនទាំងនោះ បានបង្កភាពអនាធិបតេយ្យ និងបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ ដែលជាកត្តាធ្វើឲ្យមានការព្រួយបារម្ភដល់ពលរដ្ឋខ្មែរនោះ ។ ការលើកឡើងរបស់ឯកអគ្គរដ្ឋទូតចប់អាណត្តិរូបនេះ គឺបានធ្វើឡើងនៅក្នុងកិច្ចជំនួបពិភាក្សា និងជម្រាបលា សម្តេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្តីទី នាព្រឹកថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨នេះ នៅទីស្តីការក្រសួងមហាផ្ទៃ ។

ឯកឧត្តម ស្យុង ប៉ បានលើកឡើងថា អាជ្ញាធរកម្ពុជាបានជួយលើការងារសន្តិសុខដូចជាការបង្រ្កាបបទល្មើសផ្សេងៗរួមមានបទល្មើសឆ្លងដែន ការជួញដូរគ្រឿងញៀន និងការប្រព្រឹត្តអំពើបេស្យាចារ្យផ្សេងៗនៅក្នុងទឹកដីប្រទេសកម្ពុជា ហើយរាល់ទង្វើរបស់ជនជាតិចិនទាំងនោះបានធ្វើឲ្យមានការថ្នាំងថ្នាក់ដល់ពលរដ្ឋកម្ពុជាទាំងមូល ។ ឯកឧត្តមឯកអគ្គរដ្ឋទូត បានបន្តថា "**មានជនល្មើសជាជនជាតិចិនមួយចំនួនបានឆ្លៀតឱកាសធ្វើសកម្មភាពបទល្មើសផ្សេងៗ ដែលធ្វើឲ្យប៉ះពាល់ដល់អារម្មណ៍ និងទឹកចិត្តរបស់ពលរដ្ឋខ្មែរ ។ តែយ៉ាងណាក្តីឯកឧត្តមបានអរគុណចំពោះក្រសួងមហាផ្ទៃ ដែលបានយកចិត្តទុកដាក់ជួយបង្រ្កាបនូវជនល្មើសដែលបានប្រព្រឹត្តបទល្មើសទាំងនេះ**"។ ជាមួយគ្នានោះដែរ ឯកឧត្តមឯកអគ្គរដ្ឋទូត បានលើកឡើងថា កម្ពុជាគឺជាមិត្តដ៏ល្អជាមួយចិនលើគ្រប់វិស័យ ហើយការធានានូវសន្តិសុខរឹងមាំនេះ គឺជាកិច្ចការមានសារៈសំខាន់បំផុតដែលភាគីទាំងពីរត្រូវបន្តមិនអាចអត់បាននោះឡើយ ។

ថ្លែងនៅក្នុងកិច្ចជំនួបនោះដែរ សម្តេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្តីទី ក៏បានសម្តែងការគាំទ្រដល់ការលើកឡើងរបស់ ឯកឧត្តម ស្យុង ប៉ ទាក់ទងនឹងការប្រព្រឹត្តរបស់ជនជាតិចិនមួយចំនួនតូច និងសន្យាថានឹងខិតខំសហការគ្នាឲ្យកាន់តែខ្លាំងក្លាបន្ថែមទៀត ក្នុងការបង្រ្កាបជនល្មើសទាំងនោះ ។ សម្តេចក្រឡាហោម ក៏បានថ្លែងអំណរអគុណចំពោះប្រជាជន និងរដ្ឋាភិបាលចិន ដែលបានជួយដល់ប្រទេសកម្ពុជានាពេលកន្លងមក និងបច្ចុប្បន្ន ដែលជំនួយទាំងនោះ គឺផ្នែកបានជួយលើកកម្ពស់សេដ្ឋកិច្ចកម្ពុជា និងការអភិវឌ្ឍនៅប្រទេសកម្ពុជានាពេលនេះ ៕

# កម្មករសំណង់ជាតិបរទេស នៅកាតា ច្រើននាក់ មិនបានទទួលប្រាក់ខែជាង១ឆ្នាំ

http://km.rfi.fr/ ដោយ ម៉ម ពិសី 26/09/2018

អង្គការ Amnesty International បានចេញរបាយការណ៍មួយ នៅថ្ងៃទី២៦កញ្ញានេះ ដោយបានលើកឡើងថា ពលករជនជាតិបរទេស ដែលកំពុងធ្វើការ ក្នុងការដ្ឋានសំណង់ សាងសង់ហេដ្ឋារចនាសម្ព័ន្ធកីឡា នៅប្រទេសកាតា ជាច្រើននាក់ មិនបានទទួលប្រាក់ខែជាងមួយឆ្នាំមកហើយ។ អង្គការឃ្លាំមើលសិទ្ធិមនុស្សនេះ បានអំពាវនាវឲ្យអាជ្ញាធរកាតា ត្រូវដោះស្រាយបញ្ហានេះ និងធ្វើការកែលម្អលក្ខខណ្ឌការងារ របស់កម្មករ ឲ្យសម ជាប្រទេសម្ចាស់ផ្ទះ រៀបចំកីឡាបាល់ទាត់ពិភពលោក។ កម្មករសំណង់ ប្រមាណ៧៨នាក់ ដែលភាគច្រើន ជាជនជាតិណេប៉ាល់ ជនជាតិឥណ្ឌា និងហ្វីលីពីន ធ្វើការក្នុងការដ្ឋានសំណង់មួយ របស់ក្រុមហ៊ុន Mercury MENA ក្នុងប្រទេសកាតា មិនបានទទួលប្រាក់ខែ ជាង១ឆ្នាំមកហើយ។ ប្រាក់ខែដែលពលករទាំងនោះមិនបានទទួលបាន មានជាមធ្យម សរុបប្រហែល១៧០០ដុល្លារ។

លោក Steve Cockburn តំណាងរបស់អង្គការAmnesty International បានលើកឡើងថា អង្គការលោក បានធ្វើការអង្កេតសាកសួរ បុគ្គលិកចំនួន៧៨នាក់ ដែលគ្រប់គ្នាសុទ្ធតែមិនបានទទួលប្រាក់ខែ។ ដូច្នេះ ចំនួនបុគ្គលិក ដែលមិនបានទទួលប្រាក់ខែ អាចមានលើសនេះទៅទៀត។ ក្រុមហ៊ុនសំណង់ បានឈប់បើកប្រាក់ខែ តាំងតែពីខែកុម្ភៈឆ្នាំ២០១៦ម្លេះ។ Amnesty International បានអំពាវនាវ ឲ្យរដ្ឋាភិបាលកាតា រកដំណោះស្រាយជាបន្ទាន់ ឲ្យដល់កម្មករទាំងនោះ ព្រោះការមិនប្រគល់ប្រាក់ខែជាច្រើនខែមកនេះ កំពុងតែបង្ករការលំបាកយ៉ាងធ្ងន់ធ្ងរ ដល់កម្មករ ព្រមទាំងក្រុមគ្រួសារពួកគេ ដែលរំពឹងទាំងស្រុងទៅលើប្រាក់ខែនេះ។ រដ្ឋាភិបាលកាតា ត្រូវតែចេញមុខដោះស្រាយ ឲ្យសមជាប្រទេសជឿនលឿន ដែលត្រៀមទទួលរៀបចំកីឡាបាល់ទាត់ពិភពលោក។ ក្រោយចេញរបាយការណ៍នេះ ក្រសួងការងារកាតា បានចេញលិខិតប្រកាសមួយ ដោយអះអាងថា ក្រុមហ៊ុនសំណង់ Mercury MENA បានចាកចេញ ឈប់រកស៊ីនៅកាតាហើយ ហើយថារដ្ឋាភិបាលកាតា កំពុងមានទំនាស់ផ្លូវច្បាប់ ជាមួយក្រុមហ៊ុននេះ។ លិខិតនេះអះអាងបន្ថែមថា សកម្មភាពរំលោភបំពានសិទ្ធិពលករ ដូចដែលរបាយការណ៍នេះបានលើកឡើង គឺរដ្ឋាភិបាលកាតា មិនអាចអត់ឱនឲ្យបានទេ។

គួរកត់សំគាល់ថា ដើម្បីត្រៀមទទួលការប្រកួតបាល់ទាត់ពិភពលោកឆ្នាំ២០២២ កាតាត្រូវសាងសង់ហេដ្ឋារចនាសម្ព័ន្ធកីឡា សំណង់ផ្លូវថ្នល់យ៉ាងច្រើនសន្ធឹកសន្ធាប់។ ក្រុមហ៊ុនសំណង់ បានប្រើកម្លាំងពលកម្មរបស់កម្មករជនបរទេស ដែលមានតម្លៃថោក។ ក៏ប៉ុន្តែកាតាមានច្បាប់ការងារដ៏តឹងតែងបំផុត តួយ៉ាង ដូចជាការហាមឃាត់ មិនឲ្យបុគ្គលិកបរទេសប្តូរថៅកែ ឬនិយោជក និងហាមមិនឲ្យចាកចេញពីកាតាទេ ដរាបណាមិនទាន់ចប់ការងារ ហើយត្រូវតែមានទិដ្ឋាកាចាកចេញ ទើបអាចត្រលប់ទៅប្រទេសដើមវិញបាន។ យោងតាមអង្គការ Amnesty International គឺការហាមឃាត់ដ៏តឹងតែងនេះហើយ ដែលជាប្រភព ធ្វើឲ្យមានការជិះជាន់ កេងប្រវ័ញ្ចកម្លាំងពលកម្មលើពលករ។

កាលពីដើមខែកញ្ញានេះ អាជ្ញាធរកាតា បានប្រកាសថា នឹងលុបចោលនូវទិដ្ឋាកាចាកចេញពីកាតា។ ប៉ុន្តែមកទល់ពេលនេះ គេមិនទាន់ដឹងថា គោលការណ៍ថ្មីនេះ នឹងចូលជាធរមាននៅពេលណានោះទេ។ លោកស្រី May Romanos មន្ត្រី Amnesty International និងជាអ្នកធ្វើរបាយការណ៍នេះ បានលើកឡើងថា រដ្ឋាភិបាលកាតា បានផ្លាស់ប្តូរបន្តិចបន្តួចខ្លះ តែយ៉ាងណា គឺវានៅយឺតណាស់ ខណៈពលករកម្មករ ព្រមទាំងក្រុមគ្រួសារពួកគេ កំពុងរងការលំបាក និងជាប់បំណុលយ៉ាងក្រាស់ក្រែល៕